# ឧបមាជីវិត




រៀបរៀងដោយ
ខ្ញុំព្រះករុណាអាត្មាភាព **ភិក្ខុសីលប្បញ្ញោ ឆៃ សុផល្លី**
**វត្តនិគ្រោធវ័ន គល់ទទឹង**

ព.ស. ២៥៥៧

# ឧបមាជីវិត

រៀបរៀងដោយ
ខ្ញុំព្រះករុណាអាត្មាភាព **ភិក្ខុសីលបញ្ញោ ឆៃ សុផល្លី**
**វត្តនិគ្រោធវ័ន គល់ទទឹង**

ព.ស. ២៥៥៧

# អារម្ភកថា

សៀវភៅឈ្មោះ **ឧបមាជីវិត**នេះ ខ្ញុំព្រះករុណារៀបរៀងឡើងជូនញោមឧបាសក **ស៊ឹម ថា** និងឧបាសិកា **ហ៉ាក់ មុំ** នៅក្នុងឱកាសបុណ្យឡើងគេហដ្ឋានថ្មី នាថ្ងៃទី ១៣ ខែមេសា ឆ្នាំ ២០១៥ ដោយខ្ញុំព្រះករុណាមិនមានអ្វីដើម្បីជូនគាត់នៅក្នុងឱកាសបុណ្យឡើងគេហដ្ឋានថ្មីនេះទេ មានតែរៀបរៀងកូនសៀវភៅឈ្មោះឧបមាជីវិតនេះជូនគាត់,ម្យ៉ាងទៀតក៏សូមជូនពរញោម ព្រមទាំងកូនចៅ សូមឲ្យបានជួបប្រទះតែពុទ្ធពរ ៤ ប្រការគឺ **អាយុៈ** សូមឲ្យញោមមានអាយុយឺនយូរ, **វណ្ណៈ** សូមឲ្យញោមពណ៌សម្បុរភ្លឺថ្លា, **សុខៈ** សូមឲ្យញោមជួបប្រទះតែសេចក្តីសុខ ទាំងសុខផ្លូវកាយ ទាំងសុខផ្លូវចិត្ត, **ពលៈ** សូមឲ្យញោមបានបរិបូណ៌ដោយកម្លាំង ពលំមាំមួនដើម្បីជាម្លប់ដ៏ត្រជាក់សម្រាប់កូនចៅ បានគោរពបូជា ។

សៀវភៅឧបមាជីវិតនេះ និយាយអំពីជីវិតរបស់មនុស្សយើងដែលមានប្រមាណតិចតួច ដែលកំពុងតែអស់ទៅ សូន្យទៅ ខ្ចីទៅ ខើចទៅ រេចរិលទៅ មិនអាចតាំងនៅយូរបាន សមដូចព្រះមានព្រះភាគទ្រង់ត្រាស់ទុកក្នុងបឋមជនសូត្រថា **ជីវិត គឺអាយុរបស់សត្វទាំងឡាយតិចតួចពេកណាស់ ដ្បិតជរាតែងនាំចូលទៅរកសេចក្តីស្លាប់ កាលបើសត្វដែលត្រូវជរានាំចូលទៅជិតសេចក្តីស្លាប់ហើយ នឹងរកអ្វីជ្រកកោនពុំមានឡើយ កាលបើបុគ្គលបានសម្លឹងឃើញភ័យនោះ ក្នុងសេចក្តីស្លាប់ហើយ ប្រាថ្នាសេចក្តីស្ងប់ ត្រូវតែលះបង់អាមិសក្នុងលោកចេញ ។** មួយទៀត ទ្រង់ត្រាស់ថា **អាយុរបស់មនុស្សទាំងឡាយនេះតិច សប្បុរសគួរខ្ពើមឆ្អើមអាយុនោះ បុគ្គលគួរប្រព្រឹត្តសុចរិតឲ្យដូចជាបុគ្គលដែលភ្លើងឆេះក្បាល ព្រោះថា ដំណើរមិនមកនៃសេចក្តីស្លាប់ មិនមានឡើយ។**

ភាពនៃបុគ្គលដែលបានធ្វើបុណ្យទុកហើយ, ភាពនៃបុគ្គលដែលមិនធ្វេសប្រហែសនៅក្នុងការសាងនូវសេចក្តីល្អ **នេះជាមង្គលដ៏ឧត្តម ។**

**សូមអនុមោទនា**!!!

**វត្តនិគ្រោធវ័ន គល់ទទឹង**

ថ្ងៃទី ១០រោជ ខែចេត្រ ឆ្នាំមមែ សប្តស័ក ព.ស. ២៥៥៨

**ភិក្ខុសីលប្បញ្ញោ នៃ សុផល្លី**

# គោរពជូន
# -ឧបាសក ស៊ឹម ថា
# -ឧបាសិកា ហាក់ មុំ

សូមប្រសិទ្ធពរជ័យ សិរីមហាប្រសើរ ចូលមានដល់ញោម ព្រមទាំងកូនចៅ ក្នុងឱកាសឡើងគេហដ្ឋានថ្មី នាថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៥

ខ្ញុំព្រះករុណា ខ្ញុំបាទ នាងខ្ញុំ ព្រមទាំងបុត្រ សូមគោរពប្រគេនបុណ្យ ដែលកើតអំពីធម្មទាននេះ ចំពោះព្រះសង្ឃគ្រប់ព្រះអង្គ, និងសូមជូនបុណ្យចំពោះពុទ្ធបរិស័ទ្ធទាំងអស់គ្នា សូមបានសម្រេចនូវសម្បត្តិទាំងពួង។

**សូមអនុមោទនា !!!**

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

សូមនមស្ការចំពោះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ។

## ជីវិតមានសេចក្តីឧបមាដោយធម៌ ៣ គឺ ៖

**១/ឧបនីយតិ ជីវិតមប្បមាយុំ** *ជីវិត គឺអាយុមានប្រមាណតិច ដ្បិតជរាតែងនាំចូលទៅរកមរណៈ ។*

**២/ជរូបនីតស្ស ន សន្តិ តាណា** *កាលបើបុគ្គលត្រូវជរានាំចូលទៅរកមរណៈហើយ រមែងមិនមានវិធីការពារឡើយ ។*

**៣/ឯតំ ភយំ មរណេ បេក្ខមានោ បុញ្ញានិ កយិរាថ សុខាវហានិ** *បុគ្គលកាលបើសម្លឹងឃើញភ័យ ក្នុងសេចក្តីស្លាប់នេះហើយ គួរតែខិតខំធ្វើបុណ្យទាំងឡាយ ដែលជាគុណជាតិនាំសេចក្តីសុខមកឲ្យ ។*

**អធិប្បាយ**

*ជាដំបូងនេះ យើងគ្រប់គ្នាត្រូវយល់ ត្រូវដឹងអំពីពាក្យថា* ***ជីវិត*** *។ តើជីវិតនេះ មានអត្ថន័យ សេចក្តីយ៉ាងណា ?*

*នៅក្នុងវចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជោតិញ្ញាណោ ជួន ណាត ភាគទី ១ ទំព័រ ២៦២ បានពន្យល់ថា ៖*

*ពាក្យថា* **ជីវិត** *នេះជាភាសាបាលី ឬភាសាសំស្រ្កឹត ប្រែជាភាសាខ្មែរបានដល់* ***កិរិយារស់នៅ****, ដូចបទវិគ្គហៈថា ៖* **ជីវិយតេតិ ជីវិតំ** *ធម្មជាតជាគ្រឿងរស់នៅនៃសត្វ, ធម្មជាតជាទីប្រព្រឹត្តទៅនៃ*

*សម្បយុត្តធម៌ ហៅថា* **ជីវិត** ។

*ជីវិតនេះប្រព្រឹត្តទៅបានដោយធម៌ ៣ យ៉ាងគឺ អាយុ ១ ភ្លើងធាតុ ១ វិញ្ញាណ ១ ។ បើធម៌ទាំង ៣ នេះ រលត់ទៅហើយ ជីវិតក៏ប្រព្រឹត្តទៅមិនបានដែរ ។ ដូច្នេះ ជីវិតនេះ ត្រូវអាស្រ័យធម៌ ៣ យ៉ាងនេះ និងជាប់ទាក់ទងដោយសមុដ្ឋាន ៤ គឺ កម្ម ១, ចិត្ត ១, ឧតុ ១, និងអាហារ ១, ។*

*ម្យ៉ាងទៀត ពាក្យថា* **ជីវិត** *នេះ គឺជា***កងទុក្ខ** *។ ហេតុអ្វីបានជាទុក្ខ ? ព្រោះមិនទៀង, វត្ថុណាមិនទៀង, វត្ថុនោះជាទុក្ខ ពោលដោយបរមត្ថធម៌ ។ ជីវិតមានចំណែកប្រកបចូល ៥ យ៉ាង ដែលហៅថា ខន្ធ ៥ នោះគឺះ*

***១-រូបខន្ធ*** *កងរូប បានដល់ រូប ២៨ មានមហាភូតរូប ៤ ឧបាទាយរូប ២៤ ដែលជាវត្ថុមានការប្រែប្រួលជាធម្មតា ។*

***២-វេទនាខន្ធ*** *កងវេទនា បានដល់ ការសោយអារម្មណ៍ជាសុខ ឬជា ទុក្ខ ។*

***៣-សញ្ញាខន្ធ*** *កងសញ្ញា បានដល់ សេចក្ដីចាំបាន ដូចជាចាំរូប ចាំសម្លេង ចាំក្លិន ចាំរសជាដើម ។*

***៤- សង្ខារខន្ធ*** *កងសង្ខារ បានដល់ ចេតសិកធម៌ ៥០ មាន ផស្សៈ ចេតនា ឯកគ្គតា ជាដើម ។*

**៥- វិញ្ញាណខន្ធ** គងវិញ្ញាណ បានដល់ ចិត្ត ៨៩ ឬ ១២១ ដួង ដែលធ្វើតួនាទីទទួលដឹងអារម្មណ៍ទៅតាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត បើពោលដោយសង្ខេប ចំណែកប្រកប របស់ជីវិតមាន ២ យ៉ាង គឺ រូបធម៌ ១ នាមធម៌ ១។

-**ខន្ធ ៥** មាន **រូប ជារូបធម៌** ។

-**ខន្ធ ៤** ទៀតគឺ វេទនា សញ្ញា សង្ខារ វិញ្ញាណ **ជានាមធម៌** ។

**ជីវិត**នេះបើគេពុំបានគិតឬប្រើគំនិត ដើម្បីស្វែងយល់ឲ្យដល់ជម្រៅអំពីអត្ថន័យនៃពាក្យនេះទេ គេហាក់ដូចជាបានយល់ ស្គាល់ ដឹងពាក្យនេះប្រាកដណាស់ទៅហើយ គឺគេគ្រាន់តែឲ្យន័យទៅលើពាក្យថា **ជីវិត** នេះ គឺត្រឹមតែជាការរស់នៅប៉ុណ្ណោះ ឃើញជាការស្រេច ដោយមិនចាំបាច់ទៅមានចម្ងល់ និងធ្វើការស្រាវជ្រាវឲ្យបានដឹង យល់ ស្គាល់អ្វីទៀតនោះទេ ។

ប៉ុន្តែ បើគេបានសិក្សាស្វែងយល់អំពីពាក្យថា **ជីវិត** នេះទៅតាមអត្ថន័យ និងជម្រៅ គេរឹតតែមានចម្ងល់ច្រើនណាស់ទៅទៀត អំពីពាក្យថា **ជីវិត** ព្រមទាំងបញ្ហាមិនចេះចប់ ដែលកើតមានជុំវិញជីវិតនេះជាអនេកប្បការ ។

-មុនកើត កំពុងកើត ក្រោយកើត អត់មានសត្វ បុគ្គលជាម្ចាស់ជីវិតឡើយ ។

*-ហេតុ បច្ច័យមានគ្រប់គ្រាន់ ក៏កើត ។*

*-ជីវិតរស់នៅបានតែមួយខណៈចិត្តៗប៉ុណ្ណោះ ។*

*-ចិត្តមិនទៀង បើខណៈណាពុំមានចិត្ត ជីវិតត្រូវរលត់ ។*

*-ចិត្តចុងក្រោយបំផុត (គឺចុតិចិត្ត)របស់ជាតិបច្ចុប្បន្ននេះ ជា* ***បច្ច័យ*** *ឲ្យចិត្តដំបូង (គឺបដិសន្ធិចិត្ត)របស់ជាតិអនាគតកើតឡើង ។*

**ជីវិតសត្វលោកដែលមានកិលេសរមែងអន្ទោលវិលវល់មិនចេះចប់នៅក្នុង វដ្តសង្សារ* ***គឺជាប់ដោយការកើត និងការស្លាប់*** *។*

**ជីវិតបច្ចុប្បន្ន* ***ជាផលវិបាករបស់កម្មពីអតីត*** *។*

**អតីតជាតិ បច្ចុប្បន្នជាតិ អនាគតជាតិ គឺជាការបន្តរបស់ចិត្តច្រើនប្រភេទដោយមិនដាច់ខ្សែ ។*

**អ្វីៗនៅលើលោកនេះ ហាក់ដូចជារបស់បញ្ឆោតទាំងអស់ (មាន) រលត់-កើត កើត- រលត់ ឃើញ-បាត់ បាត់-ឃើញ បែក- ជួប ជួប-បែក ។*

**ន ចាបិ វិត្តេន ជរំ វិហន្តិ**

បុគ្គលកម្ចាត់បង់នូវ **ជរា** ដោយទ្រព្យពុំបានឡើយ ។

**១/ឧបនីយតិ ជីវិតមប្បមាយុំ** *ជីវិតគឺអាយុមានប្រមាណតិច ជីវិតជរាតែងនាំចូលទៅរកមរណៈ ។*

**សេចក្តីនៃចំណុចទីមួយនេះ** *នៅក្នុងគម្ពីរសារត្ថបកាសនី អដ្ឋកថាសំយុត្តនិកាយ សគាថវគ្គ បានពន្យល់ពាក្យថា* ***ឧបនីយតិ*** *បានដល់ រមែងអស់ទៅដោយជុំវិញ រមែងរលត់ ឬថា រមែងមកដល់ គឺរមែងចូលដល់មរណៈដោយលំដាប់ ។ ម្យ៉ាងទៀត អធិប្បាយថា ហ្វូងគោដែលនាយគោបាលបានគៀងទៅរកគោលដៅ យ៉ាងណាជីវិតនេះក៏យ៉ាងនោះដែរ ត្រូវជរាគៀងទៅរកសេចក្តីស្លាប់ ។សមដូចព្រះគាថា ដែលទ្រង់ត្រាស់នៅក្នុងបិដកលេខ ៥២, ប្រារព្ធនឹងស្រ្តីនៅក្នុងនគរសាវត្ថី ប្រមាណ ៥០០ នាក់ ជាអ្នករក្សានូវឧបោសថសីល។ គ្រានោះ នាងវិសាខាចូលទៅរកស្រ្តីចាស់ៗក្នុងចំណោមស្រ្តីទាំង ៥០០ នោះហើយ សួរថា ម្នាលនាងទាំងឡាយ ពួកនាងរក្សាឧបោសថដើម្បីអ្វី ? ស្រ្តីចាស់ៗទាំងនោះប្រាប់ថា ពួកខ្ញុំរក្សាឧបោសថប្រាថ្នាទិព្វសម្បត្តិ,នាងក៏សួរពួកស្រ្តីវ័យកណ្តាលៗ ពួកស្រ្តីទាំងនោះប្រាប់ថា ពួកខ្ញុំរក្សាឧបោសថ ព្រោះចង់ផុតចាកការនៅដោយស្រ្តីរួមប្តី (ប្តីមានប្រពន្ធពីរ), នាងក៏សួរពួកស្រីវ័យក្រមុំៗ ពួកស្រីក្រមុំៗទាំងនោះប្រាប់ថា ពួកខ្ញុំរក្សាឧបោសថ ព្រោះចង់បានកូនប្រុសក្នុងគភ៌ជាដំបូង, នាងក៏សួរពួកស្រីវ័យជំទង់ ស្រី*

ទាំងនោះប្រាប់ថា ពួកខ្ញុំរក្សាឧបោសថ ព្រោះចង់បានទៅកាន់ត្រកូលប្ដីក្នុងវ័យក្រមុំៗ, នាងវិសាខា បានស្ដាប់ពាក្យរបស់ស្ត្រីទាំងនោះហើយ ក៏នាំទៅកាន់សម្នាក់ព្រះសាស្ដា ក្រាបទូលសេចក្ដីប្រាថ្នារបស់ស្ត្រីទាំងនោះ តាមលំដាប់ ។

ព្រះសាស្ដា ទ្រង់ព្រះសណ្ដាប់នូវពាក្យនោះហើយ ត្រាស់ថា ធម្មតាសភាវធម៌ទាំងឡាយ មានជាតិជាដើម របស់សត្វទាំងនេះ ដូចជានាយគោបាល ដែលមានរំពាត់ក្នុងដៃ, ជាតិ បញ្ជូនសព្វសត្វទៅកាន់ជរា ជរាបញ្ជូនទៅកាន់សម្នាក់ព្យាធិ ព្យាធិ បញ្ជូនទៅកាន់សម្នាក់មរណៈ មរណៈរមែងកាត់ផ្ដាច់ជីវិត ដូចជាបុគ្គលកាត់ដើមឈើដោយពូថៅដូច្នោះ, សូម្បីដូច្នោះក៏ដោយ ពួកសត្វក៏នៅតែមិនប្រាថ្នាវិវដ្ដៈ (ព្រះនិព្វាន), ពេញចិត្តតែវដ្ដៈប៉ុណ្ណោះ, កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្ដែងធម៌ បានត្រាស់គាថានេះថា៖

**"គង្វាលគោ រមែងកៀងគោទៅកាន់ទីគោចរ ដោយអាជ្ញាដូចម្ដេចមិញ ជរា និងមច្ចុ តែងកៀងអាយុរបស់សត្វទាំងឡាយ ដូច្នោះឯង"។**

កាលចប់ទេសនា ជនជាច្រើននាក់បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នោះឯង ។

✍ ព្រះពុទ្ធអង្គទ្រង់ត្រាស់អំពីជីវិតរបស់មនុស្សសត្វ មានប្រមាណតិចតួចណាស់ ខ្ចីណាស់ ឆាប់រេចរឹល ឆាប់សឹក ឆាប់របេះរបោច រង្គោះរង្គើ ធ្លុះធ្លាយ ពុកផុយណាស់ មិនជាប់មាំពូកែទេ ។ សូម្បីម្ចាស់ជីវិតមានមធ្យោបាយគ្រប់គ្រាន់ សម្រាប់ធ្វើឲ្យជីវិតរស់នៅក៏ជីវិតនោះមិនព្រមរស់នៅឋិតថេរ យឺនយូរបេរកាលដែរ ។ បុគ្គលដែលស្លាប់បាត់បង់ជីវិតទៅពុំមែនសុទ្ធតែស្លាប់ដោយអត់បាយ អត់ទឹក ម្ហូបចំណី ប្រដាប់ប្រដាប្រើប្រាស់ប៉ុណ្ណោះទេ មនុស្សខ្លះស្លាប់ក្នុងកណ្ដាលទ្រព្យសម្បត្តិ មានរបស់របរវត្ថុប្រើប្រាស់ ម្ហូបអាហារ ទីសេនាសនៈ ឱសថ កេសជ្ជៈគ្រប់បរិបូណ៌, ប៉ុន្តែពេលវេលាថ្ងៃ ខែ ឆ្នាំដែលកន្លងទៅនោះ ពុំមែនកន្លងទៅទទេៗទេ គឺសុទ្ធតែស្រូបយកជីវិតទៅជាមួយគ្រប់នាទីទាំងអស់ ។ ជីវិតនេះត្រូវសេចក្ដីទុក្ខគ្របសង្កត់ ជិះជាន់ បោមពោម ឡោមព័ទ្ធគ្រប់ពេល ឥតមានទំនេរ ស្រាកស្រាន្តសោះឡើយ ។ ដរាបណាមនុស្សមាន **អវិជ្ជា តណ្ហា** បិទបាំង សេចក្ដីទុក្ខគ្រប់យ៉ាងរបស់ជីវិត ក៏នៅមានដរាបនោះ ។

នៅក្នុង **អរកានុសាសនីសូត្រ**, បិដកលេខ ៤៧ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ **អំពីជីវិតមានប្រមាណតិច** ដែលនិយាយទាក់ទងនឹងគ្រូម្នាក់ឈ្មោះ **អរកៈ** ជាអ្នកធ្វើនូវកំពង់ទៅកាន់សុគតិភព ជាអ្នកប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ឯគ្រូនោះមាន

សាវ័កច្រើនរយ ។ ក្នុងសម័យនោះ ពួកមនុស្សមានអាយុ ៦០០០០ ឆ្នាំ ។ កុមារិកាមានអាយុត្រឹម ៥០០ ឆ្នាំ ទើបល្មមមានប្តី ។ ហើយសម័យនោះដែរ ពួកមនុស្សមានតែអាពាធ ៦ យ៉ាងគឺ រងា ១ ស្អុះ ១ ឃ្លាន ១ ស្រេក ១ ឈឺឧច្ចារៈ ១ ឈឺបស្សាវៈ ១។ ហើយគ្រូនោះតែងសម្តែងធម៌ទូន្មានកូនសិស្សរបស់ខ្លួនយ៉ាងនេះថា ៖

**ម្នាលព្រាហ្មណ៍** ជីវិតពួកមនុស្សជារបស់តិច ខ្លី មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន។ អ្នកទាំងឡាយត្រូវដឹង ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយសុទ្ធតែស្លាប់ ។

**ម្នាលព្រាហ្មណ៍**! ប្រៀបដូចដំណក់ទឹកសន្សើម លើចុងស្មៅដល់ព្រះអាទិត្យរះឡើង ក៏ត្រឡប់បាត់វិញឆាប់រហ័ស ជារបស់មិនឋិតថេរនៅយូរយារបាន យ៉ាងណា ម្នាលព្រាហ្មណ៍ ជីវិតរបស់ពួកមនុស្សជារបស់តិច ខ្លី មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ប្រៀបដូចដំណក់ទឹកសន្សើម យ៉ាងនោះដែរ។ អ្នកទាំងឡាយត្រូវដឹង ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយសុទ្ធតែស្លាប់ ។

**ម្នាលព្រាហ្មណ៍** ! ប្រៀបដូចភ្លៀងមានដំណក់ដ៏ថ្លោសធ្លាក់ចុះមក ក្រពេញទឹកក៏ត្រឡប់បាត់ទៅវិញឆាប់ មិនឋិតថេរ នៅយូរ

យារបាន យ៉ាងណា ម្នាលព្រាហ្មណ៍ ជីវិតរបស់ពួកមនុស្សជារបស់តិច ខ្លី មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ប្រៀបដូចជាក្រពេញទឹក យ៉ាងនោះដែរ ។ អ្នកទាំងឡាយត្រូវដឹង ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយសុទ្ធតែស្លាប់ ។

**ម្នាលព្រាហ្មណ៍** ! ប្រៀបដូចស្នាមគំនូសដម្បងលើទឹក តែងត្រឡប់បាត់ទៅវិញឆាប់ មិនឋិតថេរ នៅយូរយារបាន យ៉ាងណា ម្នាលព្រាហ្មណ៍ ជីវិតរបស់ពួកមនុស្សជារបស់តិច ខ្លី មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ប្រៀបដូចស្នាមគំនូសដម្បងលើទឹក យ៉ាងនោះដែរ ។ អ្នកទាំងឡាយត្រូវដឹង ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយ សុទ្ធតែស្លាប់ ។

**ម្នាលព្រាហ្មណ៍** ! ប្រៀបដូចស្ទឹងហូរពីភ្នំ ហូរទៅកាន់ទីឆ្ងាយ មានខ្សែទឹករហ័ស អាចនាំទៅនូវរបស់ដែលគួរនាំទៅបាន គ្មានកំណត់កាល កំណត់វេលា កំណត់យាមឡើយ ព្រោះស្ទឹងនោះចេះតែទៅ ចេះតែប្រព្រឹត្តទៅ ចេះតែហូរទៅបាន យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ ជីវិតរបស់ពួកមនុស្សជារបស់តិច ខ្លី មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ប្រៀបដូចជាស្ទឹងហូរពីភ្នំ យ៉ាង

នោះដែរ ។ អ្នកទាំងឡាយត្រូវដឹង ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្ម-ចរិយធម៌ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយ សុទ្ធតែស្លាប់ ។

**ម្នាលព្រាហ្មណ៍**! ប្រៀបដូចបុរសដែលមានកម្លាំងគ្រលៀវដុំទឹកមាត់ដាក់លើចុងអណ្ដាតហើយស្ដោះចោលទៅដោយងាយបាន ម្នាលព្រាហ្មណ៍ ជីវិតរបស់ពួកមនុស្សជារបស់តិច ខ្លី មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ប្រៀបដូចជាដុំទឹកមាត់ យ៉ាងនោះដែរ។ អ្នកទាំងឡាយត្រូវដឹង ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយសុទ្ធតែស្លាប់ ។

**ម្នាលព្រាហ្មណ៍**! ប្រៀបដូចដុំសាច់ដែលគេយកទៅដាក់ក្នុងខ្ទះដែកដ៏ក្ដៅអស់មួយថ្ងៃ រមែងខ្លោច ចង្រុះធាប់ មិនឋិតថេរ យូរយារបាន យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ ជីវិតរបស់ពួកមនុស្សជារបស់តិច ខ្លី មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ប្រៀបដូចដុំសាច់ យ៉ាងនោះដែរ ។ អ្នកទាំងឡាយត្រូវដឹង ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយសុទ្ធតែស្លាប់ ។

**ម្នាលព្រាហ្មណ៍**! ប្រៀបដូចមេគោដែលត្រូវសម្លាប់ ដែលគេនាំទៅកាន់កន្លែងសម្លាប់ ឈានជំហានណាទៅ ឈ្មោះថា ខិតទៅជិតកន្លែងសម្លាប់ ជិតសេចក្ដីស្លាប់យ៉ាងណាមិញ ម្នាលព្រាហ្មណ៍

ជីវិតរបស់ពួកមនុស្សជារបស់តិច ខ្លី មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ប្រៀបដូចជាមេគោដែលត្រូវសម្លាប់ យ៉ាងនោះដែរ ។ អ្នកទាំងឡាយត្រូវដឹង ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយ សុទ្ធតែស្លាប់ ។

➲ ម្នាលភិក្ខុទាំងឡាយ គ្រូឈ្មោះអរកៈនោះ អម្បាលពួកមនុស្សមានអាយុវែងយ៉ាងនេះ ឋិតថេរយូរយារយ៉ាងនេះ មានអាពាធតិចយ៉ាងនេះ ម្ដេចគង់សម្ដែងធម៌ដល់ពួកសាវ័កយ៉ាងនេះថា **ម្នាលព្រាហ្មណ៍** ជីវិតពួកមនុស្សជារបស់តិច ខ្លី មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ។ អ្នកទាំងឡាយត្រូវដឹង ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយសុទ្ធតែស្លាប់ ។

ម្នាលភិក្ខុទាំងឡាយ ក្នុងកាលឥឡូវនេះ បើបុគ្គលនិយាយឲ្យត្រូវ ត្រូវនិយាយថា ជីវិតពួកមនុស្សជារបស់តិចខ្លីមានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ។ អ្នកទាំងឡាយត្រូវដឹង ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ដោយប្រាជ្ញា ព្រោះសត្វដែលកើតហើយសុទ្ធតែស្លាប់។

ចំណែកនៅក្នុង **ឧបនេយ្យសូត្រ**, បិដកលេខ ២៩ កាលនោះព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទៀបក្រុងសាវត្ថី ។

*កាលរាត្រីបឋមយាមកន្លងទៅហើយ មានទេវតាមួយអង្គ មានរស្មីដ៏រុងរឿង ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបទូលព្រះមានព្រះភាគដូច្នេះថា ៖*

*ជីវិត គឺអាយុរបស់សត្វទាំងឡាយតិចតួចពេកណាស់ ដ្បិតជរាតែងនាំចូលទៅរកសេចក្តីស្លាប់ ហើយកាលបើសត្វដែលត្រូវជរានាំចូលទៅជិតសេចក្តីស្លាប់ហើយ នឹងរកអ្វីជ្រកកោនពុំមានឡើយ កាលបើបុគ្គលបានសម្លឹងឃើញភ័យនោះ ក្នុងសេចក្តីស្លាប់ហើយ គួរតែធ្វើបុណ្យទាំងឡាយ ដែលជាគុណជាតនាំសុខមកឲ្យ ។*

**ព្រះមានព្រះភាគទ្រង់ត្រាស់តបថា៖**

***ជីវិត គឺអាយុរបស់សត្វទាំងឡាយតិចតួចពេកណាស់ ដ្បិតជរាតែងនាំចូលទៅរកសេចក្តីស្លាប់ កាលបើសត្វដែលត្រូវជរានាំចូលទៅជិតសេចក្តីស្លាប់ហើយ នឹងរកអ្វីជ្រកកោនពុំមានឡើយ កាលបើបុគ្គលបានសម្លឹងឃើញភ័យនោះ ក្នុងសេចក្តីស្លាប់ហើយ ប្រាថ្នាសេចក្តីស្ងប់ ត្រូវតែលះបង់អាមិសក្នុងលោកចេញ ។***

*ម្យ៉ាងទៀត នៅក្នុង* ***ទុតិយអាយុសូត្រ****, បិដកលេខ ២៩ កាលនោះព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទៀបក្រុងរាជ-គ្រឹះ ។ កាលព្រះអង្គទ្រង់គង់នៅក្នុងទីនោះ បានត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អាយុរបស់មនុស្សនេះតិចពេក*

ណាស់ សត្វដែលត្រូវទៅកាន់បរលោក គួរធ្វើកុសល គួរប្រព្រឹត្ត ព្រហ្មចរិយធម៌ សត្វដែលកើតហើយ ឈ្មោះថា មិនស្លាប់មិនមាន ទេ ម្នាលភិក្ខុទាំងឡាយ បុគ្គលរស់នៅយ៉ាងយូរត្រឹម ១០០ ឆ្នាំ ឬ ថយតិចចុះក៏មាន លើសជាងបន្តិចទៅក៏មាន ។

គ្រានោះស្រាប់តែមារមានចិត្តបាប បានចូលសំដៅទៅរក ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលនឹងព្រះមាន ព្រះភាគដូច្នេះថា ៖

***បើថ្ងៃ និងយប់ មិនកន្លងទៅ ជីវិតក៏មិនរួញថយចុះដែរ អាយុ នៃសត្វទាំងឡាយ តែងប្រព្រឹត្តទៅតាម(ថ្ងៃនិងយប់) ដូចខ្នងកង់ដែល វិលទៅតាមក្បាលក្រពើនៃរទេះ ។***

**ព្រះមានព្រះភាគទ្រង់ត្រាស់តបថា៖**

***ថ្ងៃនិងយប់តែងកន្លងទៅ ជីវិតតែងរួញថយចុះមក អាយុរបស់ សត្វទាំងឡាយ ចេះតែអស់ទៅ ដូចជាទឹកស្ទឹងតូចទាំងឡាយ ។***

គ្រានោះឯង មារមានចិត្តបាបកើតទុក្ខ តូចចិត្តថា ព្រះមាន ព្រះភាគស្គាល់អញ ព្រះសុគតស្គាល់អញ ដូច្នេះហើយ ក៏អន្តរធាន ចាកទីនោះទៅ ។

ម្យ៉ាងទៀតនៅក្នុង **អច្ចេន្តិសូត្រ**, បិដកលេខ ២៩ កាលនោះ ព្រះមានព្រះ ភាគទ្រង់គង់នៅក្នុងក្រុងសាវត្ថី ។ពេលនោះ មានទេវ

តាមួយអង្គ បានចូលទៅក្រាបថ្វាយបង្គំ ហើយបានពោលពាក្យនេះក្នុងសំណាក់នៃព្រះអង្គថា ៖

កាលទាំងឡាយតែងកន្លងទៅរាត្រីទាំងឡាយ តែងឆ្លងហួសទៅជំនាន់នៃវ័យទាំងឡាយតែងលះបង់នូវលំដាប់កាល បុគ្គលបានសម្លឹងឃើញភ័យនោះក្នុងសេចក្ដីស្លាប់ហើយ គួរតែធ្វើបុណ្យទាំងឡាយ ដែលជាគុណជាតនាំសេចក្ដីសុខមកឲ្យ ។

**ព្រះមានព្រះភាគទ្រង់ត្រាស់តបថា៖**

កាលទាំងឡាយតែងកន្លងទៅ រាត្រីទាំងឡាយតែងឆ្លងហួសទៅ ជំនាន់នៃវ័យទាំងឡាយតែងលះបង់នូវលំដាប់ កាលបុគ្គលបានសម្លឹងឃើញភ័យនោះក្នុងសេចក្ដីស្លាប់ហើយ ជាអ្នកសម្លឹងឃើញសេចក្ដីស្ងប់ គួរតែលះបង់អាមិសក្នុងលោកចេញ ។

ម្យ៉ាងទៀត នៅក្នុង**បឋមអាយុសូត្រ**, បិដកលេខ២៩ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទៀបក្រុងរាជគ្រឹះ ។ កាល ព្រះមានព្រះភាគទ្រង់គង់នៅក្នុងទីនោះ បានត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ក៏ទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថាព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ **អាយុរបស់មនុស្សទាំងឡាយនេះតិចណាស់ សត្វដែលត្រូវទៅកាន់បរលោក គួរធ្វើកុសល**

គួរប្រព្រឹត្តព្រហ្មចរិយធម៌ សត្វដែលកើតហើយឈ្មោះថា មិនស្លាប់ មិនមានទេ ម្នាលភិក្ខុទាំងឡាយ បុគ្គលរស់នៅយ៉ាងយូរត្រឹម ១០០ ឆ្នាំ ឬថយតិចចុះក៏មាន លើសជាងបន្តិចទៅក៏មាន ។

គ្រានោះឯង ស្រាប់តែមារមានចិត្តបាប បានចូលសំដៅទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលនឹងព្រះមានព្រះភាគដូច្នេះថា ៖

**អាយុរបស់មនុស្សទាំងឡាយវែង សប្បុរសមិនគួរខ្ពើមឆ្អើមអាយុនោះឡើយ បុគ្គលគួរប្រព្រឹត្តខ្លួនឲ្យដូចជាកូនក្មេងស្រវឹងទឹកដោះ ព្រោះថា ដំណើរមកនៃមច្ចុមិនមានទេ ។**

**ព្រះមានព្រះភាគទ្រង់ត្រាស់តបថា៖**

**អាយុរបស់មនុស្សទាំងឡាយតិច សប្បុរស គួរខ្ពើមឆ្អើមអាយុនោះ បុគ្គលគួរខំប្រព្រឹត្តសុចរិត ឲ្យដូចបុគ្គលដែលភ្លើងឆេះក្បាល ព្រោះថា ដំណើរមិនមកនៃសេចក្តីស្លាប់ មិនមានឡើយ ។**

គ្រានោះឯង មារមានចិត្តបាបកើតទុក្ខ តូចចិត្តថា ព្រះមានព្រះភាគស្គាល់អញ ព្រះសុគតស្គាល់អញ ដូច្នេះហើយ ក៏អន្តរធានចាកទីនោះទៅ ។

ឯនៅក្នុង **ធនុគ្គហសូត្រ**, បិដកលេខ ៣២ ព្រះអង្គទ្រង់ត្រាស់អំពីជីវិតដែលអស់ទៅលឿនរហ័ស ជាមួយនឹងភិក្ខុទាំងឡាយថា ៖

**ម្នាលភិក្ខុទាំងឡាយ** មានខ្មាន់ធ្នូ ៤ នាក់ មានកម្លាំងមាំមួន បានសិក្សាដោយប្រពៃ មានសិល្បៈស្ទាត់ក្នុងដៃ បានសម្តែងសិល្បៈរួចហើយ ឈរនៅក្នុងទិសទាំង៤។ ហើយកាលនោះ មានបុរសម្នាក់ដើរមកគិតថា កាលខ្មាន់ធ្នូទាំង ៤ នាក់នេះ ជាអ្នកស្ទាត់ជំនាញក្នុងការបាញ់កូនសរទៅក្នុងទិសទាំង៤ បើមិនទាន់ធ្លាក់ដល់ដីដរាបណា អាត្មាអញអាចចាប់យកកូនសរទាំងនោះបាន ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សំទុះនៃបុរស(អ្នកបាញ់កូនសរ)នោះយ៉ាងណាក្តី ។ សំទុះនៃបុរសដែល(រត់ចាប់កូនសរនោះ)យ៉ាងណាក្តី, សំទុះនៃព្រះច័ន្ទនិងព្រះអាទិត្យ ដែលលឿនជាងសំទុះបុរសនោះយ៉ាងណាក្តី ។ សំទុះនៃបុរសនោះយ៉ាងណាក្តី សំទុះនៃព្រះច័ន្ទនិងព្រះអាទិត្យយ៉ាងណាក្តី ។ សំទុះនៃទេវតាទាំងឡាយ ដែលស្ទុះទៅពីមុខព្រះច័ន្ទ និងព្រះអាទិត្យយ៉ាងណាក្តី ។ សំទុះនៃបុរសនោះយ៉ាងណាក្តី សំទុះនៃព្រះច័ន្ទ និងព្រះអាទិត្យយ៉ាងណាក្តី សំទុះនៃទេវតាទាំងឡាយ ដែលស្ទុះទៅអំពីខាងមុខព្រះច័ន្ទ និងព្រះអាទិត្យយ៉ាងណាក្តី, **(ម្នាលភិក្ខុទាំងឡាយ) អាយុ(ជីវិតរបស់សត្វ)ទាំងឡាយ អស់ទៅលឿនរហ័សជាងសំទុះទាំងនោះទៅទៀត** ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ **អ្នកទាំងឡាយចូរជាអ្នកមិនប្រមាទ ចូរសិក្សាយ៉ាងនេះចុះ** ។

ម្យ៉ាងទៀត **ជីវិតតិច, ជីវិតស្ដួចស្ដើង** ដោយហេតុ ២យ៉ាងគឺ ៖

**១/ជីវិតតិច** ព្រោះធម្មជាតិតាំងនៅតិច ។

**២/ជីវិតតិច** ព្រោះកិច្ចរបស់ខ្លួនតិច ។

✪. **ជីវិតតិច** ព្រោះធម្មជាតតាំងនៅតិច តើមានន័យដូចម្ដេច ? គឺសត្វទាំងឡាយដែលរស់នៅហើយ ក្នុងខណៈចិត្តជាអតីត មិនកំពុងរស់នៅក្នុងបច្ចុប្បន្ន និងមិនរស់នៅក្នុងអនាគតទេ ។ សត្វនឹងរស់នៅក្នុងខណៈចិត្តជាអនាគត មិនកំពុងរស់នៅក្នុងបច្ចុប្បន្ន មិនរស់នៅហើយក្នុងអតីតទេ ។ សត្វដែលកំពុងរស់នៅក្នុងខណៈចិត្តជាបច្ចុប្បន្ន មិនបានរស់នៅហើយក្នុងអតីត នឹងមិនរស់នៅក្នុងអនាគតទេ ។

ជីវិត អត្តភាព សុខនិងទុក្ខទាំងអស់ ប្រកបដោយខណៈចិត្តតែមួយ ព្រោះខណៈចិត្តប្រព្រឹត្តទៅរហ័ស ពួកទេវតាណាឋិតនៅអស់ ៨៤ ពាន់កប្ប ទេវតាទាំងនោះ មិនមែនប្រកបដោយចិត្ត ២ ហើយរស់នៅទេ ខន្ធទាំងឡាយណារបស់បុគ្គលដែលស្លាប់ទៅក្ដី រស់នៅក្ដី រលត់ហើយក្នុងលោកនេះ ខន្ធទាំងឡាយនោះ ក៏ដូចគ្នាទៅបដិសន្ធិទៀតមិនបាន ។ ខន្ធទាំងឡាយណាដែលកន្លងទៅជាលំដាប់ បែកធ្លាយហើយផង ខន្ធទាំងឡាយណា ជាអនាគត នឹងបែកធ្លាយផង សេចក្ដីផ្សេងៗគ្នានៃខន្ធទាំងឡាយណា ជាបច្ចុប្បន្នដែលរលត់ហើយក្នុងចន្លោះនៃខន្ធទាំងពីរនោះ រមែងមិនមានក្នុង

លក្ខណៈ សត្វលោកដែលកើតហើយដោយអនាគត ខន្ធដែលមិនទាន់កើត មិនឈ្មោះថា រស់នៅហើយ ទាំងមិនឈ្មោះថា កំពុងរស់នៅក្នុងខន្ធជាបច្ចុប្បន្នទេ សត្វលោកស្លាប់ ដោយការបែកធ្លាយនៃចិត្ត (នេះជា) **បញ្ញត្តនៃបរមត្ថ** ការប្រែប្រួលទៅដោយឆន្ទៈ ដូចជាទីទាប រមែងប្រព្រឹត្តទៅដូច្នោះ វេទនាទាំងឡាយ មានសឡាយតនៈជាបច្ច័យ មានវារៈមិនដាច់ តែងប្រព្រឹត្តទៅ ខន្ធទាំងឡាយដែលបែកធ្លាយហើយក៏មិនដល់នូវការតម្កល់ទុកគំនរនៃខន្ធ ក្នុងអនាគតក៏មិនមាន ខន្ធទាំងឡាយដែលកើតឡើងហើយ រមែងឋិតនៅដូចគ្រាប់ស្ពៃ ដែលស្ថិតនៅលើចុងដែកស្រួច កាលបើខន្ធទាំងឡាយកើតឡើងហើយ ការបែកធ្លាយនៃខន្ធទាំងនោះ ក៏ស្ថិតនៅខាងមុខសភាវៈដែលត្រូវវិនាសទាំងឡាយ (ខន្ធ)កំពុងឋិតនៅមិនច្រឡូកច្រឡំដោយខន្ធចាស់ទេ រមែងមកអំពីទីមើលមិនឃើញ លុះបែកធ្លាយហើយ តែងទៅកាន់ទីមើលមិនឃើញវិញ រមែងកើតឡើងផងរមែងវិនាសទៅផង ដូចជាផ្លេកបន្ទោរឰដ៏អាកាស ។ **ជីវិតតិច ព្រោះការរស់នៅតិចយ៉ាងនេះឯង ។**

**៥. ជីវិតតិច** ព្រោះកិច្ចរបស់ខ្លួនតិច តើមានន័យដូចម្តេច ? គឺជីវិតជាប់ទាក់ទងដោយដង្ហើមចូល, ជីវិតជាប់ទាក់ទងដោយដង្ហើមចេញ, ជីវិតជាប់ទាក់ទងដោយដង្ហើមចូល និងដង្ហើមចេញ, ជីវិតជាប់ទាក់ទងដោយមហាភូតរូប, ជីវិតជាប់ទាក់ទងដោយភ្លើង

ធាតុ, ជីវិតជាប់ទាក់ទងដោយអាហារជាពំនូត, ជីវិតជាប់ទាក់ទងដោយវិញ្ញាណ ។ ឫសគល់របស់ធម៌ទាំងនេះ មានកម្លាំងថយ ។ សូម្បីពួកធម៌ជាបច្ច័យ ធម៌ទាំងនោះ ក៏មានកម្លាំងថយ ។ សូម្បីពួកធម៌ណា ប្រកពធម៌ទាំងនោះ ក៏មានកម្លាំងថយ ។ ធម៌ណាដែលកើតជាមួយនឹងធម៌ទាំងនេះ ក៏មានកម្លាំងថយ ។ ពួកធម៌ប្រកបជាមួយគ្នានឹងធម៌ទាំងនេះក៏មានកម្លាំងថយ ។ ធម៌ដែលកើតឡើង ជាមួយនឹងធម៌ទាំងនេះ ក៏មានកម្លាំងថយ ។

ធម្មជាតណា ជាគ្រឿងប្រកបដោយជាតិនោះ ក៏មានកម្លាំងថយ ។ ធម៌ទាំងនេះមានកម្លាំងថយជានិច្ចដល់គ្នានិងគ្នា ។ ធម៌ទាំងនេះមិនឱនរកគ្នានិងគ្នា ។ ធម៌ទាំងនេះញាំងគ្នានិងគ្នាឲ្យធ្លាក់ចុះ ។ ព្រោះមិនជាទីពឹងដល់គ្នានិងគ្នា ។ មួយវិញទៀត ធម៌ទាំងនេះមិនតម្កល់ទុកនូវគ្នានិងគ្នា ។ សូម្បីធម៌ណាជាអ្នកបង្កើត ធម៌នោះ ក៏មិនមាន ។ ធម៌ណាមួយ មិនមែនវិនាសដោយធម៌ណាមួយទេ ។ ព្រោះធម៌ទាំងនេះ បែកធ្លាយទៅដោយប្រការទាំងពួង ។ ធម៌ទាំងនេះ កើតឡើងហើយព្រោះហេតុ និងបច្ច័យអំពីមុន ។ ហេតុនិងបច្ច័យណាដែលកើតមុន ហេតុ និងបច្ច័យទាំងនោះ ក៏ស្លាប់មុនទៅហើយ ។ ធម៌ទាំងឡាយខាងដើម និងខាងចុង មិនបានឃើញគ្នានិងគ្នា ក្នុងកាលណាមួយឡើយ ។ **ជីវិតតិច ព្រោះកិច្ចរបស់ខ្លួនតិចយ៉ាងនេះ។**

*ពិតណាស់ សត្វខ្លះកើតមកបានកន្លះខែក្តី, មួយខែក្តី, កន្លះឆ្នាំក្តី, មួយឆ្នាំក្តី, ប៉ែតសិបឆ្នាំក្តី, កៅសិបឆ្នាំក្តី, ច្យុត, ស្លាប់, បាត់បង់, វិនាសទៅវិញក៏មាន ហេតុនោះ(ទ្រង់ត្រាស់ថា)* ***ជីវិតនេះតិចណាស់ រមែងស្លាប់ខាងអាយ អំពី ១០០ ឆ្នាំ បើបុគ្គលណា រស់នៅកន្លងហួស (ពី ១០០ ឆ្នាំ)ទៅ បុគ្គលនោះគង់ស្លាប់ ព្រោះជរាពុំខាន ។***

*ពាក្យថា* ***សត្វរមែងស្លាប់ខាងអាយ អំពី ១០០ ឆ្នាំ*** *អធិប្បាថា ៖*

-**សត្វរមែងច្យុត** *ស្លាប់ បាត់បង់ វិនាស ក្នុងកាលជាកលលៈក៏មាន ។*

-**សត្វរមែងច្យុត** *ស្លាប់ បាត់បង់ វិនាស ក្នុងកាលជាអម្ពុទៈ ក៏មាន ។*

-**សត្វរមែងច្យុត** *ស្លាប់ បាត់បង់ វិនាស ក្នុងកាលជាបេសិក៏មាន ។*

-**សត្វរមែងច្យុត** *ស្លាប់ បាត់បង់ វិនាស ក្នុងកាលជាឃនៈក៏មាន ។*

-**សត្វរមែងច្យុត** *ស្លាប់ បាត់បង់ វិនាស ក្នុងកាលជាបញ្ចសាខា ក៏មាន ។*

-**សត្វគ្រាន់តែមានកំណើត** *ច្យុត ស្លាប់ បាត់បង់ វិនាស ក៏មាន ។*

*ពាក្យថា* ***បើបុគ្គលណា រស់នៅកន្លងហួសទៅ*** *គឺបុគ្គលណា*

រស់នៅកន្ទង៍១០០ឆ្នាំទៅ បុគ្គលនោះ រស់នៅអស់មួយឆ្នាំក្តី ពីរឆ្នាំក្តី, រស់នៅអស់សាមសិបឆ្នាំក្តី, រស់នៅអស់សែសិបឆ្នាំក្តី ហេតុនោះ (ទ្រង់ត្រាស់ថា) បើបុគ្គលណា រស់នៅកន្ទង៍ហួសទៅ ។

ពាក្យថា **បុគ្គលនោះគង់ស្លាប់ ព្រោះជរាពុំខាន** អធិប្បាយថា កាលណាបុគ្គលចាស់ ចម្រើនដោយវ័យ មានអាយុច្រើន កន្ទង៍កាល ជ្រុលចូលក្នុង៍បច្ឆិមវ័យ មានធ្មេញបាក់ សក់ស្កូវ ក្បាលឆកស្បែកជ្រីវជ្រួញ ខ្នង៍កោង៍កាន់ឈើច្រត់ បុគ្គលនោះគង់ច្យុត ស្លាប់ បាត់បង់ វិនាស ព្រោះជរា ។

៚. ជីវិតរបស់យើង៍គ្រប់គ្នានេះ ខើចទៅរាល់ថ្ងៃ អស់ទៅរាល់ថ្ងៃចាប់តាំង៍ពីថ្ងៃចុះចាប់បដិសន្ធិក្នុង៍ផ្ទៃនៃមាតាមក យើង៍បានចាយជីវិតបណ្តើរៗទៅហើយ ប្រសូតចាកគភ៌មាតាភ្លាម ក៏ចាយបន្តទៅទៀត រហូតដល់អស់តែម្តង៍ ប្រៀបដូចជាបុគ្គលមានលុយនៅក្នុង៍ហោប៉ាវ ឬកាបូប ដោយមិនដឹង៍ថា លុយរបស់ខ្លួននឹង៍មានចំនួនប៉ុន្មានទេ តែបានដកចាយមួយថ្ងៃ១០០០ ឬមួយថ្ងៃ ១០០០០ រៀល, ដកចាយរាល់ថ្ងៃ ហើយក៏មិនដឹង៍ថា លុយនៅក្នុង៍ហោប៉ាវនឹង៍សល់ប៉ុន្មានទៀតទេ ។ បុគ្គលកាលសម្លឹង៍ឃើញជីវិតរបស់ខ្លួនខើចទៅអស់ទៅ ខ្វិទៅ រេចទៅ តិចទៅ តូចទៅ យ៉ាង៍នេះត្រូវកុំប្រមាទនៅក្នុង៍ការសាង៍នូវសេចក្តីល្អឡើយ ត្រូវរក្សាខ្លួនទុកនៅក្នុង៍អំពើល្អ ត្រូវ

*យកការសាងសេចក្តីល្អនេះឲ្យជាប្រធានលើអ្វីៗទាំងអស់ ត្រូវបង្កើតមុខរបរមួយសម្រាប់ខ្លួនគឺ* **មុខរបរស្វែងរកបុណ្យ។** *ព្រោះថា បើមិនខិតខំធ្វើបុណ្យទេ ឥតមានបុណ្យថ្មីសម្រាប់ផ្តល់នូវសេចក្តីសុខតទៅជាតិខាងមុខទៀតទេ ហើយឥឡូវនេះ កុំភ្លេចយើងរស់នៅដោយសារបុណ្យចាស់ទេ ត្រូវគិតផង ត្រូវខិតខំសាងបុណ្យថ្មីផង ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា* **ឧបនីយតិ ជីវិតមប្បមាយុំ ជីវិតគឺអាយុមានប្រមាណតិច ដ្បិតជរាតែងនាំចូលទៅរកមរណៈ ។**

**២/ ជរូបនីតស្ស ន សន្តិ តាណា** *កាលបើបុគ្គលត្រូវជរានាំចូលទៅរកមរណៈហើយ រមែងមិនមានវិធីការពារឡើយ ។*

**សេចក្តីនៃចំណុចទីពីរនេះ** *នៅក្នុងគម្ពីរសារត្ថបកាសនី អដ្ឋកថាសំយុត្តនិកាយ សគាថវគ្គ បានពន្យល់ថា កាលបុគ្គលចូលដល់ជរាហើយ ឬថា កាលបុគ្គលត្រូវជរានាំចូលទៅកាន់សំណាក់នៃសេចក្តីស្លាប់ហើយ* ***ន សន្តិ តាណា*** *នរណាៗឈ្មោះថា អាចដើម្បីការពារគ្នាបានគឺឲ្យសេចក្តីមិនមានភ័យឲ្យទីពឹងឲ្យទីអាស្រ័យបាននោះ គឺមិនមានឡើយ ។*

*សេចក្តីនេះ គឺចង់សម្តែងបញ្ជាក់ថា បុគ្គលដែលត្រូវជរា នាំចូលទៅរកសេចក្តីស្លាប់ហើយ មិនមានវិធីការពារថា មិនឲ្យចាស់ មិនឲ្យឈឺ មិនឲ្យស្លាប់បានឡើយ គឺត្រូវតែចាស់ ឈឺ ស្លាប់ ត្រូវតែលះបង់នូវអ្វីៗ គ្រប់យ៉ាងនៅក្នុងលោកនេះ ព្រោះហេតុនោះ បានជាព្រះអង្គសម្តែងនៅក្នុងបិដកលេខ ៥២ ប្រារព្ធនឹងនាង* ***បដាចារ*** *ដែលមានសេចក្តីទុក្ខដ៏ធំមហិមា គឺប្តីរបស់នាងស្លាប់, កូនទាំងពីររបស់នាងស្លាប់, ឪពុកម្តាយ និងបងប្រុសរបស់នាងក៏ស្លាប់ ក្នុងថ្ងៃតែមួយ នាងត្រូវសេចក្តីទុក្ខគ្រប់សង្កត់យ៉ាងខ្លាំង រហូតដល់បាត់បង់សតិស្មារតី ដើរអត់មានសម្លៀកបំពាក់ ក្រោយមកដោយអំណាចបុណ្យបារមីដែលនាងបានបំពេញមក ក៏ធ្វើឲ្យនាងឈាន*

ដើរដើរចូលទៅក្នុងវត្តជេតពន គ្រានោះព្រះអង្គក៏ទ្រង់ត្រាស់ថា ចូរនាងមានសតិស្មារតីឡើងវិញ ដោយអំណាចពាក្យតម្រាស់ប៉ុណ្ណោះ នាងក៏មានស្មារតីឡើងវិញ ហើយក៏បានអង្គុយយំ រៀបរាប់អំពីសេចក្ដីទុក្ខរបស់ខ្លួន ដែលព្រាត់ប្រាស់នូវបិយជន (ជនជាទីស្រឡាញ់) ឲ្យព្រះអង្គជ្រាប ពេលនោះព្រះអង្គក៏សម្ដែងព្រះគាថានេះថា ៖

***កាលបុគ្គលត្រូវមច្ចុគ្របសង្កត់ហើយ កូនទាំងឡាយមិនមានដើម្បីជាទីពឹង បិតាក៏មិនមាន ទាំងផៅពង្សក៏មិនមានដើម្បីជាទីពឹងឡើយ សេចក្ដីទីពឹងក្នុងញាតិទាំងឡាយ ក៏មិនមាន បណ្ឌិតដឹងអំណាចប្រយោជន៍នេះហើយ គួរជាអ្នកសង្រួមក្នុងសីល គួរជាអ្នកជម្រះផ្លូវជាទីទៅព្រះនិព្វានឲ្យបាន ។***

ជាការពិតណាស់ ជាសច្ចធម៌ ជាធម្មជាតិពិត មនុស្សយើងម្នាក់ៗដែលបានកើតមកហើយមិនអាចគេចផុតអំពីរបស់បីនោះទេ ព្រោះរបស់បីនេះ គឺជាមត៌កនៃជីវិត ។ របស់បីនោះគឺ ចាស់ ១ ឈឺ ១ ស្លាប់ ១, របស់ទាំងបីនេះគឺបានជិតជាម ជាប់តាមជីវិតតាំងតែពីចុះចាប់បដិសន្ធិក្នុងផ្ទៃនៃមាតាមកម្ល៉េះ ហើយក៏មិនមានថ្នាំបន្សាបណានៅក្នុងលោកនេះ ឬព្រហ្មលោក មារលោក អាចព្យាបាល កុំឲ្យចាស់ ឈឺ ស្លាប់បានដែរ ។ ព្រោះប្រទេសនៅលើផែនដីនេះ ដែលបុគ្គលឋិតនៅហើយ អាចគេចផុតអំពីការ ចាស់ ឈឺ ស្លាប់

បាននោះគឺមិនមានសោះឡើយ សមដូចព្រះអង្គទ្រង់ត្រាស់នៅក្នុងបិដកលេខ ៥២ ប្រារព្ធនឹងព្រះបាទសុប្បពុទ្ធ, បើយើងនិយាយតាមសាមញ្ញធម្មតា គឺព្រះបាទសុប្បពុទ្ធនេះ ត្រូវជាឪពុកក្មេករបស់ព្រះអង្គ ព្រោះព្រះនាងយសោធរា ហៅពិម្ពា ត្រូវជាកូនរបស់ព្រះបាទសុប្បពុទ្ធ តែព្រះបាទសុប្បពុទ្ធនេះ នៅថ្ងៃមួយ គាត់បានស្ទាក់ផ្លូវមិនឲ្យព្រះអង្គនិមន្តទៅបិណ្ឌបាត ពេលនោះព្រះអង្គក៏បានត្រាស់ថា ព្រះបាទសុប្បពុទ្ធនេះ ៧ ថ្ងៃទៀត ផែនដីនឹងស្រូប គ្រានោះព្រះបាទសុប្បពុទ្ធក៏បានតបទៅព្រះអង្គវិញថា ខ្ញុំព្រះអង្គនឹងឡើងទៅលើប្រាសាទ ៧ជាន់ចាំមើលធរណីស្រូបខ្ញុំព្រះអង្គយ៉ាងម៉េច ។ ចាប់តាំងពីថ្ងៃនោះមក ព្រះបាទសុប្បពុទ្ធបានឡើងទៅលើប្រាសាទ ៧ ជាន់ ហើយបានដាក់ទាហាន យាមការពារគ្រប់ជាន់ ដោយអនុញ្ញាតឲ្យតែមនុស្សម្នាក់ សម្រាប់យកក្រយាហារទៅថ្វាយប៉ុណ្ណោះ នឹងបានផ្ដាំពួកទាហានទាំងអស់នោះទៀតថា ប្រសិនបើយើងមានការភ្លេចភ្លាំងស្មារតី ចុះមកខាងក្រោម សូមចាប់យើងទៅដាក់ខាងលើវិញ ។ ថ្ងៃទី ១ ទី ២ទី ៣ ទី ៤ ទី ៥ ទី ៦ ព្រះអង្គភ្លេចខ្លួនចុះមក ពួកទាហានបានចាប់ព្រះអង្គទៅដាក់ខាងលើវិញ តែដល់ថ្ងៃទី ៧ នេះ សេះដែលព្រះអង្គធ្លាប់ជិះ វាក៏បានស្រែកកញ្ជ្រៀវឡើង ធ្វើឲ្យព្រះអង្គនៅមិនសុខ ទ្រង់ក៏បានចុះមក ហើយគ្រានោះ ពួក

ទាហានយាមការពារទាំងឡាយ ក៏មិនបាននឹក ដើម្បីចាប់ព្រះអង្គទៅដាក់ខាងលើដូចមុនទៀតឡើយ គ្រាកាលព្រះអង្គចុះមកដល់ដីផែនដីក៏បានស្រូបធ្លាក់ទៅសោយទុក្ខនៅក្នុង អវីចិនរកទៅ ក្រោយមកព្រះអង្គទ្រង់ត្រាស់ព្រះគាថានេះថា ៖

**បុគ្គលទៅឰដ៏អាកាស ក្នុងកណ្ដាលសមុទ្រ កាន់ចន្លោះនៃភ្នំទាំងឡាយ ក៏មិនរួចចាកសេចក្ដីស្លាប់បាន ព្រោះប្រទេសលើផែនដីដែលបុគ្គលឋិតនៅហើយ សេចក្ដីស្លាប់គ្របសង្កត់មិនបាននោះ មិនដែលមានឡើយ ។**

ម្យ៉ាងទៀតនៅក្នុង **គម្ពីរឃ្លាំងបរិយត្តិ** លោកបានសម្ដែងអំពីអំណាចរបស់មច្ចុរាជ ដែលនៅក្នុងលោកនេះ មិនមានអំណាចណាមួយអាចប្រៀបផ្ទឹមបានឡើយ គឺ ៖

១-យក្ខ បិសាច ប្រេត ពេលដែលខឹងក្រោធហើយ រមែងចូលទៅស្ថិតនៅក្នុងខ្លួនមនុស្សបាន តែមិនអាចចូលទៅស្ថិតក្នុងខ្លួនរបស់ **មច្ចុរាជ** បានឡើយ ។

២-ពួកមនុស្សអាចធ្វើការបន់ស្រន់ បួងសួងនូវយក្ខ បិសាច ឬប្រេត ដែលខឹងក្រោធឲ្យចេញបាន តែមិនអាចបន់ស្រន់ បួងសួងអង្វរករ **នូវមច្ចុរាជ** បានឡើយ ។

៣-ព្រះរាជាអាចដាក់អាជ្ញាចំពោះអ្នកប្រព្រឹត្តខុស អ្នកចង់

ដណ្ដើមយកនូវរាជសម្បត្តិ និងអ្នកដែលបៀតបៀនមនុស្សទាំងឡាយតាមសមគួរបាន តែមិនអាចដាក់អាជ្ញាបំពោះ **មច្ចុរាជ** បានឡើយ ។

៤-បុគ្គលដែលប្រព្រឹត្តខុស គិតដណ្ដើមយកនូវរាជសម្បត្តិ និងអ្នកដែលបៀតបៀនមនុស្សទាំងឡាយ អាចមានឱកាសសូមឲ្យព្រះរាជា អត់ឱនទោសឲ្យបាន តែមិនអាចសុំឲ្យ **មច្ចុរាជ** អត់ឱនទោសឲ្យបានឡើយ ។

៥-**មច្ចុរាជ** មិនមានសេចក្ដីអាល័យ ត្រេកអរថា បុគ្គលនេះជាក្សត្រ បុគ្គលនេះជាព្រាហ្មណ៍ (បុគ្គលនេះជាមាតា បុគ្គលនេះជាបិតា បុគ្គលនេះជាកូន...) ឬជាបុគ្គលមាំមួន មានតេជៈច្រើនឡើយ ។

៦-រាជសីហ៍ ខ្លាដំបង ខ្លារខិន រមែងញាំញី ទំពាស៊ីនូវសត្វសត្វបាន តែមិនអាចញាំញី ទំពាស៊ីនូវ **មច្ចុរាជ** បានឡើយ ។

៧-បុគ្គលអ្នកលេងកលល្បិច កាលប្រើនូវកលល្បិចក្នុងទីលាន (កីឡាជាដើម) រមែងអាចបន្លំភ្នែករបស់មហាជនឲ្យវង្វេងជឿបាន តែមិនអាចបន្លំភ្នែក **មច្ចុរាជ** បានឡើយ ។

៨-អាសិរពិស ដែលមានពិសសាហាវ ពេលខឹងក្រោធពួកមនុស្សហើយ រមែងចឹក ខាំមនុស្សឲ្យដល់នូវសេចក្ដីស្លាប់បាន តែមិនអាចចឹក ខាំនូវ **មច្ចុរាជ** បានឡើយ ។

៩-អាសិរពិស ពេលខឹងក្រោធ ចិកខាំនូវបុគ្គលណាហើយ គ្រូពេទ្យ រមែងអាចបន្សាបនូវពិសបាន តែមិនអាចបន្សាបពិសរបស់ **មច្ចុរាជ** បានឡើយ ។

១០-គ្រូពេទ្យដែលមានឈ្មោះល្បីល្បាញ រមែងអាចកម្ចាត់នូវពិសរបស់ស្តេចនាគបាន តែគ្រូពេទ្យទាំងនោះ ត្រូវស្លាប់ទាំងអស់ លុះក្នុងអំណាចនៃ **មច្ចុរាជ** ។

១១- ពួកវិជ្ជាធរ កាលរាយវិជ្ជាឈ្មោះមោរៈ រមែងបបាំងខ្លួនបាន តែមិនអាចបបាំងខ្លួនកុំឲ្យ **មច្ចុរាជ** ឃើញបានឡើយ ។

១២-បុគ្គលដែលប្រកបដោយកម្លាំងកាយក្តីកម្លាំងចិត្តក្តី និងអាចយកឈ្នះកម្លាំងរបស់ **មច្ចុរាជ** បាននោះ គឺមិនមានឡើយ ។

១៣-ព្រះរាជាអាចញាំញីនូវសេនាប្រកបដោយអង្គ ៤ ដែលគួរឲ្យញញើតបាន ហើយដណ្តើមយកជ័យជម្នះបាន តែមិនអាចយកជ័យជម្នះលើសេនារបស់ **មច្ចុរាជ** បានឡើយ ។

១៤-ព្រះរាជាដែលក្លាហាន រមែងបង្ក្រាបនូវនគររបស់សត្រូវឲ្យចុះចូល តែមិនអាចបង្ក្រាបនូវសេនារបស់ **មច្ចុរាជ** បានឡើយ ។

១៥-ព្រះរាជាអាចលោមព័ទ្ធដោយកម្លាំងពលទាំង ៤ ហើយអាចរួចផុតអំពីក្រញាំដៃរបស់សត្រូវបាន តែមិនអាចរួចផុតអំពីក្រញាំដៃរបស់ **មច្ចុរាជ** បានឡើយ ។

១៦-ដំរីចុះប្រេង អាចជាន់ញាំញីនូវនគរទាំងឡាយនិងអាច សម្លាប់នូវមនុស្សទាំងឡាយបាន តែមិនអាចញាំញី សម្លាប់នូវសេនារបស់ **មច្ចុរាជ** បានឡើយ ។

១៧-នាយព្រានធ្នូ ដែលបានហ្វឹកហាត់មកល្អហើយ អាចយិតធ្នូបានឆ្ងាយ និងបាញ់បានត្រង់ មិនភ្លាត់ តែមិនអាចបាញ់ឲ្យត្រូវ ចំ នូវសេនារបស់ **មច្ចុរាជ** បានឡើយ ។

✪. **មច្ចុរាជ** នេះ គឺជាយក្ខ ដែលទំពាស៊ីនូវជីវិតរបស់សព្វសត្វទាំងឡាយឲ្យអស់ទៅ ឲ្យខ្ចីទៅ ឲ្យខើចទៅ...ជារៀងរាល់ថ្ងៃ ។ និង **មច្ចុរាជ** នេះ ប្រៀបដូចជាភ្នំថ្មតាន់ ដ៏ធំទូលាយ ទល់នឹងអាកាស ហើយរលំចុះមកកិននូវពួកសត្វដែលឋិតនៅក្នុងទិសទាំង ៤ ដូច្នោះ ។ **មច្ចុរាជ** នេះទំពាស៊ីនូវជីវិតរបស់មនុស្សគ្រប់គ្នា ទោះបីអ្នកនោះ ជាព្រះពុទ្ធ ជាព្រះបច្ចេកពុទ្ធ ជាព្រះអគ្គសាវ័ក ជាព្រះអរិយសាវ័ក អរិយសាវិកា ជាសេដ្ឋី ជាគហបតី ជាគហបតីមហាសាល ជាព្រះសង្ឃក្តី ក្សត្រក្តី អ្នកមានយសក្តី អ្នកឥតយសក្តី អ្នកមានក្តី អ្នកក្រក្តី បណ្ឌិតក្តី ពាលក្តី អ្នកមានរូបល្អក្តី អ្នកមានរូបអាក្រក់ក្តី អ្នកធ្វើល្អក្តី អ្នកធ្វើអាក្រក់ក្តី ជាដើម អ្នកទាំងអស់នេះក៏មិនមានវិធីការពារ ឲ្យរួចផុតអំពីកណ្តាប់មាត់របស់មច្ចុរាជបានឡើយ ។ **អ្នកទាំងអស់នេះ ត្រូវបង់ពន្ធន៍ជីវិតឲ្យ មច្ចុរាជ** ក្នុងមួយ

ថ្ងៃ **២៤ ម៉ោង ស្មើៗគ្នា** មិនមានតិចច្រើនជាងគ្នានោះឡើយ ។ ព្រោះហេតុដូច្នោះ តើយើងត្រូវគិតយ៉ាងណា? ត្រូវប្រញាប់ប្រញាល់ធ្វើអំពើល្អឬក៏ត្រូវធ្វេសប្រហែសក្នុងការសាងល្អម្យ៉ាងទៀត យើងកុំភ្លេចពាក្យមួយថា

**បោលអ្វីបោលបាន តែកុំបោលប្រាណ ឈានធ្លាក់រណ្តៅ**

**បើបានជាភ្នាត់ កុំឲ្យធ្លាក់ជ្រៅ ប្រឹងឡើងណាពៅ កុំនៅនាំជ្រួល ។**

បោលមាស បោលប្រាក់ បោលយស បោលសក្តិ បោលកូន បោលប្តី បោលប្រពន្ធ បោលផ្ទះ បោលដី ស្រែ ចំការជាដើម បោលទាំងអស់នេះ គឺជាការបោលធម្មតាទេ តែអ្វីដែលសំខាន់ជាងនេះទៅទៀតនោះគឺកុំបោលខ្លួនឯងទៅក្នុងអំពើអាក្រក់ឲ្យសោះ ត្រូវតែខិតខំសាងខ្លួនឡើងឲ្យតាំងនៅក្នុងអំពើល្អ ណាមួយដំណើរជីវិតរបស់នេះ មិនមានយកអ្វីទៅក្រៅតែអំពីសេចក្តីល្អរបស់យើងឡើយ ។ សមដូចព្រះមានព្រះភាគ ទ្រង់ត្រាស់ថា **ជរូបនីតស្ស ន សន្តិ តាណា** កាលបើបុគ្គលត្រូវជរានាំចូលទៅរកមរណៈហើយ រមែង**មិនមានវិធីការពារឡើយ ។** រឿងសេចក្តីល្អនេះ នឹងមាននិយាយជាបន្តនៅក្នុងចំណុចខាងក្រោម ។

**៣/ឯតំ ភយំ មរណេ បេក្ខមានោ បុញ្ញានិ កយិរាថ សុខាវហានិ** *បុគ្គលកាលបើសម្លឹងឃើញភ័យ ក្នុងសេចក្ដីស្លាប់នេះហើយ គួរតែខិតខំធ្វើបុណ្យទាំងឡាយ ដែលជាគុណជាតិនាំសេចក្ដីសុខមកឲ្យ ។*

**សេចក្ដីនៃចំណុចទីបីនេះ** *នៅក្នុងគម្ពីរសារត្ថបកាសនី អដ្ឋកថាសំយុត្តនិកាយ សគាថវគ្គ បានពន្យល់ពាក្យថា **ឯតំ ភយំ** គឺបានដល់ភ័យ ៣ យ៉ាងគឺ ភ័យអំពីសេចក្ដីស្លាប់ ១ ភ័យអំពីការមានអាយុតិច ១ ភ័យអំពីការមិនបានធ្វើនូវទីពឹង គឺសេចក្ដីល្អរបស់បុគ្គលដែលត្រូវជរានាំចូលទៅរកមរណៈ ១ ។*

*លោកក៏បានពន្យល់ពាក្យតទៅទៀតថា **បុញ្ញានិ កយិរាថ សុខាវហានិ** គឺវិញ្ញូជនដែលជាបណ្ឌិត ជាសប្បុរស (កាលបើបានឃើញនូវភ័យនៃសេចក្ដីស្លាប់នេះហើយ) គប្បីខិតខំធ្វើបុណ្យទាំងឡាយ ដែលជាគុណជាតនាំសេចក្ដីសុខមកឲ្យ ។*

*ពាក្យថា* **បុណ្យ** *នេះ គឺជាភាសាសំស្ក្រឹត, ភាសាបាលីថា* **បុញ្ញៈ** *បើជាភាសាខ្មែរថា **ជម្រះ** ឬ **សម្អាត់** ។ សមដូចបទវិគ្រោះដែលលោកចងទុក នៅក្នុង**គម្ពីរអភិធានប្បទីបិកាសូចិ** ថា ៖*

**សន្តានំ បុនាតិ សោធេតីតិ → បុញ្ញំ** *ប្រែថា ធម្មជាតឯណាដែលជម្រះសន្តានចិត្តឲ្យស្អាតបាន ធម្មជាតនោះ ឈ្មោះថា* **បុណ្យ** *ដូច្នេះ ។*

*ន័យមួយទៀតថា៖* **បុណ្យ** *លោកសំដៅយក* ***សេចក្ដីសុខចម្រើន ដែលត្រូវបានដល់អ្នកធ្វើ ។*** *ដូចមានព្រះពុទ្ធភាសិតសម្ដែងទុកនៅក្នុងគម្ពីរ អង្គុត្តរនិកាយ សត្តនិបាតថា៖* **មា ភិក្ខវេ បុញ្ញានំ ភយិត្ថ សុខស្សេតំ ភិក្ខវេ អធិវចនំ យទិទំ បុញ្ញានំ** *សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ* ***អ្នកទាំងឡាយកុំខ្លាចបុណ្យឲ្យសោះ ។*** *ម្នាលភិក្ខុទាំងឡាយ ព្រោះពាក្យដែលហៅថា* **បុណ្យនុ៎ះ** មិនគឺអ្វីដទៃ *ឡើយគឺជាឈ្មោះនៃសេចក្ដីសុខ,សេចក្ដីសុខនុ៎ះសោត ក៏ជាសេចក្ដីសុខរបស់បុណ្យ ដូច្នេះ ។*

*ព្រះពុទ្ធភាសិតនេះ ព្រះសម្មាសម្ពុទ្ធបរមគ្រូជាម្ចាស់ ទ្រង់ត្រាស់ទេសនាថា បើបុរសស្ត្រីណាមួយបានធ្វើបុណ្យ ត្រូវខិតខំធ្វើបុណ្យនោះឲ្យរឿយៗគឺទ្រង់ដាស់តឿនពុទ្ធបរិស័ទឲ្យប្រឹងធ្វើបុណ្យដែលជាហេតុ គឺជាធម្មជាតិជម្រះសន្ដានចិត្តឲ្យប្រាសចាកសេចក្ដីលោភៈទោសៈ មោហៈ ឲ្យញឹកញាប់ដើម្បីយកបុណ្យដែលជាផលគឺសេចក្ដីចម្រើននោះឯង ព្រោះអ្នកដែលបានធ្វើចិត្តឲ្យប្រាសចាកអកុសល ៣ យ៉ាងជាដើមនោះ បានឈ្មោះថា* ***អ្នកមានចិត្តជាបុណ្យ ។*** *ធម្មជាតិរបស់អ្នកមានចិត្តជាបុណ្យនោះឯង តែងធ្វើនូវបុញ្ញកិរិយាវត្ថុទាំងឡាយមាន ការធ្វើទាន រក្សាសីល ចំរើនមេត្តាភាវនាជាដើម បានដោយងាយ, ការធ្វើទាន រក្សាសីល ចម្រើន*

ការនោហ្នឹងហើយ លោកហៅថា **ធ្វើបុណ្យ** ។ បុណ្យនេះហើយ ដែលជាហេតុផ្តួចផ្តើម ឲ្យកើតកម្រៃផល គឺសេចក្តីសុខសប្បាយ ដោយយសសក្តិ សម្បត្តិ បរិវារ អាយុយឺនយូរ និងសតិបញ្ញាឲ្យ បានផលជាតិនេះ និងបរជាតិ គឺជាតិខាងមុខ ។

**បុណ្យ** កាលកើតឡើងហើយ រមែងតាក់តែងនូវចិត្តឲ្យមាន សភាពល្អឡើងធ្វើឲ្យចិត្តអាចជ្រើសរើសគិតចំពោះរឿងណា ដែល ល្អ ត្រូវ ដែលគួរ ដែលមានប្រយោជន៍ ហើយនិយាយបានល្អ ធ្វើ បានល្អ តាមដែលគិតនោះ ។

**បុណ្យនេះ** ពិតមែន តែមនុស្សយើងទូទៅមើលដោយភ្នែក មិនឃើញក៏ដោយ តែក៏អាចដឹងនូវអាការៈរបស់បុណ្យឬផលរបស់ បុណ្យបាន គឺកាលបុណ្យកើតឡើងហើយ រមែងតាក់តែងនូវចិត្ត ឲ្យសប្បាយ រីករាយត្រជាក់ស្ងប់ ប្រៀបបាននឹងភ្លើងអគ្គិសនីយ៍ សូម្បីយើងមើលមិនឃើញតួភ្លើងដោយត្រង់តែយើងអាចទទួលដឹង អាការៈរបស់ភ្លើងបាន ដូចពេលដែលភ្លើងនោះចូលទៅក្នុងអំពូល ភ្លើងហើយ ក៏មានពន្លឺឡើង ឬកាលភ្លើងនោះឆ្លងចូលទៅក្នុងកង្ហារ ឬម៉ាស៊ីនត្រជាក់ហើយ សេចក្តីត្រជាក់ រមែងកើតឡើងជាដើម ។

បុណ្យដែលកើតឡើងហើយ តែងសន្សំទុកនៅក្នុងចិត្តទាំង អស់ មិនសាបសូន្យទៅណាទេ សូម្បីបុគ្គលនោះធ្វើមរណកាល

ទៅ ចិត្តរមែងនាំយកនូវបុណ្យនោះ ចូលភព ចូលជាតិទៅ ។

កាលយើងទម្លាប់ចូលចិត្តធ្វើបុណ្យឲ្យរឿយៗ ចិត្តរបស់យើង នឹងពេញទៅដោយបុណ្យហើយកិលេសផ្សេងៗនឹងមិនមានឱកាស គ្របសង្កត់ចិត្តយើងបានឡើយ ធ្វើឲ្យចិត្តត្រជាក់ស្ងប់មិនមានសេចក្ដី កង្វល់ ដូចជាមិនគិតចង់បានទ្រព្យសម្បត្តិអ្នកដទៃ មិនជាប់ជំពាក់ ក្នុងវត្ថុកាមផ្សេងៗ គិតតែពីសាងសេចក្ដីល្អឲ្យខ្លួនឯងប៉ុណ្ណោះ ។

ចំពោះពាក្យថា **បុណ្យនេះ** គឺជាឈ្មោះនៃសេចក្ដីសុខ, សេចក្ដីសុខ ក៏គឺជាឈ្មោះរបស់បុណ្យ ព្រោះហេតុនោះ បុគ្គល ដែលប្រាថ្នានូវសេចក្ដីសុខដល់ខ្លួននោះ ត្រូវខំសាងបុណ្យឲ្យបាន ច្រើន និងឲ្យប្រញាប់ប្រញាល់រួសរាន់ កុំបង្អែបង្អង់យូរឡើយ ។ ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ទ្រង់ត្រាស់ទុកនៅក្នុង **បាបវគ្គ គាថាធម្មបទ**, បិដកលេខ៥២ថាៈ

**អភិត្ថរេថ កល្យាណេ បាបា ចិត្តំ និវារយេ ទន្ធំ ហិ ករតោ បុញ្ញំ បាបស្មឹ រមតី មនោ ។** បុគ្គលគួរប្រញាប់ប្រញាល់ ធ្វើអំពើល្អ គួរឃាត់ចិត្តចាកបាប ព្រោះថា កាលបើបុគ្គលធ្វើបុណ្យ យឺតយូរ ចិត្តរមែងត្រេកអរក្នុងបាប ។

សេចក្ដីនេះនៅក្នុងគម្ពីរអដ្ឋកថា គាថាធម្មបទ លោកក៏បាន ពន្យល់ថាៈគប្បីធ្វើភ្លាមៗគឺថា ឲ្យឆាប់ៗ ។ ពិតណាស់ បុគ្គលណា

ទោះបីជាបុរសក្តី ស្ត្រីក្តី កាលបើចិត្តកើតឡើងថា នឹងធ្វើកុសលណាមួយ មានការធ្វើទានជាដើម គួរធ្វើភ្លាមៗ គឺថា ធ្វើឲ្យឆាប់ៗ ដោយគិតថា យើងនឹងធ្វើមុន ។ កុំឲ្យបុគ្គលដទៃបានឱកាសធ្វើមុនឲ្យសោះៗ ឬបើជាបព្វជិត កាលធ្វើវត្តទាំងឡាយ មានឧបជ្ឈាយវត្តជាដើម គឺមិនឲ្យឱកាសដល់បព្វជិតដទៃ គួរធ្វើឲ្យឆាប់ៗ ដោយគិតថា យើងនឹងធ្វើមុន ។ ហើយបុគ្គលគប្បីហាមឃាត់ចិត្តចាកបាបកម្ម មានកាយទុច្ចរិតជាដើម ឬអកុសលចិត្តប្បាទក្នុងទីទាំងពួង ។ ក៏បុគ្គលណាវល់តែគិតយ៉ាងនេះថា យើងនឹងឲ្យទាន, នឹងយើងធ្វើបុណ្យ, តើផលនឹងសម្រេចដល់យើង ឬក៏មិនសម្រេចហ្ន៎? នេះឈ្មោះថា ធ្វើបុណ្យយឺតយូរ ដូចជាបុគ្គលដើរតាមផ្លូវរអិល, ចិត្តបាបរបស់បុគ្គលនោះរមែងបានឱកាស ដូចមច្ឆរិយចិត្ត ១០០០ ដួងរបស់ព្រាហ្មណ៍ឈ្មោះឯកសាដក ដូច្នោះៗ កាលបើបុគ្គលធ្វើបុណ្យយឺតយូរ ដូច្នេះ ចិត្តរមែងត្រេកអរក្នុងបាប, ព្រោះថា ក្នុងវេលាដែលធ្វើបុណ្យប៉ុណ្ណោះ ទើបចិត្តនេះត្រេកអរក្នុងកុសល, ផុតអំពីនោះហើយ រមែងបង្អោនទៅរកអំពើអាក្រក់ដោយពិត ។

នៅក្នុង **ជរាសូត្រ**, បិដកលេខ ២៩ មានទេវតាមួយអង្គ មានរស្មីដ៏រុងរឿង នាពាក់កណ្តាលអធ្រាត្រ បានចូលទៅគាល់ព្រះសម្មាសម្ពុទ្ធ លុះចូលទៅដល់ហើយបានក្រាបថ្វាយបង្គំព្រះអង្គ រួចក៏អង្គុយនៅក្នុងទីដ៏សមគួរលុះអង្គុយក្នុងទីដ៏សមគួរហើយ ក៏បាន

ទូលសួរនូវចម្លល់របស់ខ្លួនថា ៖

**កឹសុ ចោរេហិ ទូហរំ** អ្វីហ្ន៎ ដែលពួកចោរនាំទៅមិនបាន ។

ព្រះមានព្រះភាគទ្រង់ត្រាស់តបថា៖

**បុញ្ញំ ចោរេហិ ទូហរំ** បុណ្យ ពួកចោរនាំទៅមិនបាន ។

សេចក្តីនេះ នៅក្នុងគម្ពីរសារត្ថបកាសនី អដ្ឋកថាសំយុត្ត-និកាយ សគាថវគ្គ លោកបានពន្យល់ថា **បុណ្យ** បានដល់ **បុញ្ញចេតនា** (គឺចេតនាជាតួបុណ្យ) ហើយចេតនានេះជាសភាវៈមិនមានរូប ដែល បុគ្គលណាៗក៏ដោយ មិនអាចនាំទៅបានឡើយ ។

ឯនៅក្នុង **មិត្តសូត្រ**, បិដកលេខ ២៩ ក៏មានទេវតាមួយអង្គមានរស្មីដ៏រុងរឿង នាពាក់កណ្តាលអធ្រាត្រ បានចូលទៅគាល់ព្រះសម្មាសម្ពុទ្ធ លុះចូលទៅដល់ហើយ បានក្រាបថ្វាយបង្គំព្រះអង្គរួចក៏អង្គុយនៅក្នុងទីដ៏សមគួរ លុះអង្គុយក្នុងទីដ៏សមគួរហើយ ក៏បានទូលសួរនូវចម្លល់របស់ខ្លួនដែរថា ៖

**កឹ មិត្តំ សម្បរាយិកន្តិ** អ្វីហ្ន៎ ជាមិត្តតាមទៅក្នុងភពខាងមុខ ។

ព្រះមានព្រះភាគទ្រង់ត្រាស់តបថា ៖

**សយំ កតានិ បុញ្ញានិ តំ មិត្តំ សម្បរាយិកំ** បុណ្យទាំងឡាយដែលគេធ្វើហើយដោយខ្លួនឯង ជាមិត្តជាប់តាមទៅក្នុងភពខាងមុខ ។

✍. រាល់អំពើល្អ សេចក្តីល្អ ដែលយើងគ្រប់គ្នាបានបំពេញ ហើយដោយកាយ វាចា ចិត្ត គឺសុទ្ធតែជាបុណ្យកុសលទាំងអស់ ។ បុណ្យនេះឯង ជាមិត្តជាប់តាមខ្លួនយើងទៅក្នុងជាតិខាងមុខ សម ដូចព្រះពុទ្ធវចនៈខាងលើ ។ បុណ្យអាចអភិសេកយើង ឲ្យបានទៅ ជាព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ជាអគ្គសាវ័ក ជាសាវ័កសាវិកាដ៏ល្អក៏ បាន ។ ព្រោះហេតុនោះ នៅក្នុង**និធិកណ្ឌសូត្រ** បិដកលេខ ៥២ ឬ ក៏នៅក្នុង **គម្ពីរឃ្លាំងបរិយត្តិភាគ ២** លោកបានសម្តែងអំពីអំណាច របស់បុណ្យថា ៖

-បុណ្យមិនមានអ្នកអាចមកដណ្តើមបាន

-បុណ្យជាប់តាមខ្លួនទៅគ្រប់ជំហាន

-បុណ្យនាំទៅកាន់ទេវលោក

-បុណ្យមិនជារបស់សាធារណៈដល់ជនដទៃ

-បុណ្យចោរនាំទៅមិនបាន

-បុណ្យធ្វើឲ្យសម្រេចនូវសេចក្តីប្រាថ្នាទាំងពួងបាន

-ប្រាថ្នារបស់ណារមែងបានរបស់នោះ ព្រោះបុណ្យ

-មានសប្បុរល្អព្រោះបុណ្យ

-មានសម្លេងពីរោះព្រោះបុណ្យ

-មានទ្រង់ទ្រាយល្អព្រោះបុណ្យ

-មានរូបល្អព្រោះបុណ្យ

-បានជាអ្នកធំព្រោះបុណ្យ

-មានបរិវារជាទីស្រឡាញ់ព្រោះបុណ្យ

-បានជាព្រះរាជាព្រោះបុណ្យ

-បានឥស្សរិយយសព្រោះបុណ្យ

-បានជាស្តេចចក្រពត្តិព្រោះបុណ្យ

-បានកើតជាមនុស្សព្រោះបុណ្យ

-បានជាទេវតាព្រោះបុណ្យ

-បានព្រះនិព្វានព្រោះបុណ្យ

-បានមិត្តល្អព្រោះបុណ្យ

-បានវិជ្ជានិងវិមុត្តិព្រោះបុណ្យ

-បែកធ្លាយក្នុងបដិសម្ភិទាទាំង ៤ ព្រោះបុណ្យ

-បានជាស្តេចទេវតាព្រោះបុណ្យ

-បានវិមោក្ខ ៣ វិមោក្ខ ៨ ព្រោះបុណ្យ

-បានជាពុទ្ធសាវ័កព្រោះបុណ្យ

-បានជាបច្ចេកពុទ្ធព្រោះបុណ្យ

-បានជាព្រះពុទ្ធក៏ព្រោះបុណ្យដែរ ។

ជីវិតរបស់បុគ្គលដែលមានបុណ្យ គឺជាជីវិតដែលមាននូវអ្វីៗ

ទាំងអស់ ជាជីវិតដែលពោរពេញទៅដោយសេចក្ដីសុខ មិនមែនដូចពាក្យគេថា មានលុយមានអ្វីៗទាំងអស់នោះទេ ព្រោះលុយមិនអាចធ្វើឲ្យយើងគេចផុតពីកើត ចាស់ ឈឺ ស្លាប់បានទ មានតែបុណ្យទេ ដែលធ្វើឲ្យយើងរួចផុតអំពីការចាស់ ឈឺ ស្លាប់ និងសេចក្ដីទុក្ខទាំងឡាយបាន ។

ម្យ៉ាងទៀត នៅក្នុង **ទុតិយសីលយសូត្រ**, បិដកលេខ ៣៩ ព្រះអង្គទ្រង់ត្រាស់ជាមួយនឹងលោកអនាថបិណ្ឌិកសេដ្ឋីអំពីបុថុជ្ជន **ដែលមិនខ្លាចស្លាប់**, ដែលកាលនោះ អនាថបិណ្ឌិកសេដ្ឋីឈឺធ្ងន់ព្រះអង្គទ្រង់ត្រាស់ថា៖

ម្នាលគហបតី អរិយសាវ័កជាអ្នកចេះដឹងច្រើន ប្រកបដោយធម៌ ៤ យ៉ាង រមែងមិនតក់ស្លុត មិនរន្ធត់ មិនខ្លាចស្លាប់ទៅខាងមុខទេ ។ **ធម៌ ៤ នោះគឺ ៖**

**ម្នាលគហបតី** អរិយសាវ័កក្នុងសាសនានេះ ជាអ្នកប្រកបដោយសេចក្ដីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធ ហើយពិចារណាឃើញសេចក្ដីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធ ។...

**ម្នាលគហបតី** ម្យ៉ាងទៀត អរិយសាវ័កជាអ្នកចេះដឹងប្រកបដោយសេចក្ដីជ្រះថ្លាមិនកម្រើកក្នុងព្រះធម៌ ហើយពិចារណាឃើញសេចក្ដីជ្រះថ្លាមិនកម្រើកក្នុងព្រះធម៌ ។...

**ម្នាលគហបតី** ម្យ៉ាងទៀត អរិយសាវ័កជាអ្នកចេះដឹង

ប្រកបដោយសេចក្តីជ្រះថ្លា មិនកម្រើកក្នុងព្រះសង្ឃ ហើយពិចារណា ឃើញសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះសង្ឃ ។...

**ម្នាលគហបតី** ម្យ៉ាងទៀត អរិយសាវ័កជាអ្នកចេះដឹងប្រកបដោយអរិយកន្តសីល ជាសីលមិនដាច់ ប្រព្រឹត្តទៅដើម្បីសមាធិ ។ កាលបើអរិយសាវ័កនោះ ពិចារណាឃើញនូវអរិយកន្ត-សីលទាំងនោះក្នុងខ្លួន រមែងមិនតក់ស្លុត មិនរន្ធត់ មិនខ្លាចស្លាប់ទៅខាងមុខឡើយ ។

ម្នាលគហបតីអរិយសាវ័កជាអ្នចេះដឹងប្រកបដោយធម៌៤នេះឯងហើយ រមែងមិនតក់ស្លុត មិនរន្ធត់ មិនខ្លាចស្លាប់ទៅខាងមុខ ។

ម្យ៉ាងទៀតនៅក្នុង ***សៀវភៅធម្មាវលី***, លោកក៏បានសម្តែងទៀត អំពីបុគ្គលដែលមិនខ្លាចស្លាប់ **ព្រោះមានធម៌ ៤ យ៉ាងគឺះ**

១/ជាបុគ្គលប្រាសចាកចាគ:(សេចក្តីតម្រេក )ក្នុងកាម

២/ជាបុគ្គលមិនមានសេចក្តីស្រឡាញ់ក្នុងកាយ

៣/ជាបុគ្គលបានធ្វើបុណ្យទុកមកច្រើន

៤/ជាបុគ្គលអស់សេចក្តីសង្ស័យ គឺបានសម្រេចធម៌ ។

ឯចំណែកនៅក្នុង **មង្គលសូត្រ**, បិដកលេខ ៥២ ព្រះអង្គបានទ្រង់ត្រាស់ជាមួយទេវតាថា៖ **បុព្វេ ច កតបុញ្ញតា** ភាពនៃបុគ្គលដែលបានធ្វើបុណ្យទុកមក **គឺជាមង្គលដ៏ឧត្តម ។**

# សូមពុទ្ធបរិស័ទ្ធសិក្សាពីជីវិតរបស់បុគ្គលមានបុណ្យ

*នៅក្នុង **បិដកលេខ ៥២**, មួយអន្ទើដោយអដ្ឋកថា គាថា-ធម្មបទ លោកបានសម្តែងអំពីជីវិតរបស់ធម្មិកឧបាសក គាត់គឺជាឧបាសកមួយរូប ដែលមានសទ្ធាជ្រះថ្លានៅក្នុងព្រះពុទ្ធសាសនា និងគាត់ក៏ជាប្រធានលើឧបាសកប្រមាណ ៥០០ នាក់ ។ ឧបាសកនេះគាត់ មានបុត្រធីតា១៤ នាក់, បុត្រធីតាទាំងអស់នោះ គឺជាកូនល្អ ចេះស្តាប់ឪវាទ, ហើយគាត់តែតែងដឹកនាំក្រុមគ្រួសារមានករិយាជាដើម ឲ្យជាអ្នកត្រេកអរក្នុងទាន, ជាអ្នកមានសីល, មានកល្យា-ណាធម៌ ,មានសេចក្តីល្អនៅក្នុងជីវិត ។ មួយជីវិតរបស់គាត់គឺមានតែអំពើល្អ ។ ក្រោយមកគាត់ក៏បានធ្លាក់ខ្លួនឈឺ ងើបមិនរួចពីគ្រែ តែគាត់មានប្រាថ្នាដើម្បីនឹងស្តាប់ព្រះធម៌ដ៏ល្អល្អះ របស់ព្រះដ៏មានព្រះភាគ ទើបបានឲ្យកូនទៅនិមន្តព្រះសង្ឃអំពីវត្តជេតពន មកដើម្បីស្វាធ្យាយព្រះធម៌ ពេលដែលព្រះសង្ឃនិមន្ត មកដល់គង់នៅលើអាសនៈហើយ គាត់ក៏បាននិយាយថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ មេត្តាស្វាធ្យាយនូវព្រះសូត្រណាមួយដល់ខ្ញុំព្រះអង្គចុះ ។*

*គ្រានោះលោកក៏បានពោលថា ម្នាលឧបាសក អ្នកចង់ស្តាប់នូវព្រះសូត្រណា? គាត់ក៏បាននិយាយតបថា សតិប្បដ្ឋានសូត្រ លោកក៏បានស្វាធ្យាយនូវសតិប្បដ្ឋានសូត្រទៅ ។ នៅពេលដែល*

គាត់កំពុងស្តាប់ធម៌នោះ ស្រាប់តែទេវតានៅក្នុងឆកាមាវចរសួគ៌ ៦ ជាន់ មានរថ ៦ គ្រឿង ប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាង ទឹមដោយសេះសិន្ធព ១០០ ទំហំ ១៥៥ យោជន៍ ឈរនៅលើអាកាស ម្នាក់ៗស្រែកអញ្ជើញគាត់ថា បពិត្រលោកដ៏ចម្រើន យើងនឹងនាំលោកទៅកាន់ឋានរបស់យើង, យើងនឹងនាំលោកទៅកាន់ឋានរបស់យើង សូមលោកកើតនៅក្នុងទីនេះ ដើម្បីសេចក្តីត្រេកអរក្នុងទេវលោករបស់យើង ដូចបុគ្គលទម្លាយភាជនៈដី ហើយកាន់យកភាជនៈមាស ។

គាត់មិនប្រាថ្នាដើម្បីឲ្យមានអន្តរាយ ដល់ការស្តាប់ព្រះធម៌ ទើបនិយាយតបថា **ចូរបង្អង់សិន ចូរបង្អង់សិន។** ឯចំណែកពួកភិក្ខុដែលកំពុងស្វាធ្យាយព្រះធម៌ និងកូនៗរបស់គាត់ មានការយល់ខុសដូច្នេះហើយលោកក៏បានឈប់សូត្រ ហើយនិមន្តទៅវត្តអស់ទៅ ។ ឯកូនរបស់គាត់ក៏បាននាំគ្នាយំ ហើយនិយាយថា ពីដើមឪពុករបស់យើងមិនឆ្អែតដោយការស្តាប់ធម៌ទេ តែឥឡូវនេះបែរជាហាមឃាត់លោកមិនឲ្យស្វាធ្យាយព្រះធម៌វិញ ដែលឈ្មោះថា សត្វមិនខ្លាចចំពោះសេចក្តីស្លាប់មិនមាន ដូច្នេះហើយក៏បាននាំគ្នាយំ ។ លុះបន្តិចក្រោយមក គាត់មានស្មារតីឡើងវិញ ឃើញកូនៗអង្គុយយំដូច្នោះក៏បានសួរថា ហេតុអ្វី បានជាពួកឯងនាំគ្នាយំ ? កូនៗក៏បានប្រាប់ថា បិតាឲ្យនិមន្តភិក្ខុមកហើយ ដើម្បីស្តាប់ធម៌ តែបែរជាហាម

ឃាត់ទៅវិញ ព្រោះដូច្នេះ ពួកខ្ញុំគិតថា ឈ្មោះថា សត្វមិនខ្លាច ចំពោះសេចក្ដីស្លាប់មិនមាន ទើបនាំគ្នាយំសោកទៅ ។ ហើយគាត់ក៏បានសួររកលោក គ្រានោះកូនៗរបស់គាត់ក៏បានប្រាប់ថា លោកនិមន្តទៅវត្តវិញហើយ ព្រោះលោកគិតថា បិតាឈប់ឲ្យសូត្រហើយ ។ គាត់ក៏បាននិយាយតបវិញថា បិតាមិនបានឃាត់លោកទេ បិតានិយាយជាមួយទេវតាទេតើ ។ កូនៗនិយាយថា ទេវតានៅឯណា ម្ដេចមិនឃើញ? ឧបាសកនោះនិយាយតបថា កម្រងផ្កាសម្រាប់បិតាមានដែរឬទេ? កូនថា មាន ហើយគាត់ក៏បានសួរកូនៗថា តើឋានមួយណា គួរជាទីត្រេកអរជាង ។ កូនៗក៏បាននិយាយថា ឋានតុសិត គឺជាទីនៅនៃព្រះពោធិសត្វគ្រប់ៗព្រះអង្គ ។ បើដូច្នោះ ពួកឯងចូរអធិដ្ឋានថា សូមកម្រងផ្កានេះ ចូរទៅជាប់នឹងរាជរថដែលមកអំពីឋានតុសិតចុះ ហើយចូរបោះទៅ ។ មហាជនឃើញតែកម្រផ្កានោះ តែមិនឃើញរាជរថទេ ។ ឧបាសកនិយាយថា អ្នកទាំងឡាយឃើញកម្រងផ្កានោះទេ ? បុត្រឆ្លើយថា ឃើញ ។ គាត់ក៏បាននិយាយទៀតថា កម្រងផ្កានោះព្យួរនៅហ្នឹងរាជរថដែលមកអំពីភពតុសិត យើងនឹងទៅកាន់តុសិត ពួកឯងកុំព្រួយ ហើយបើពួកឯងមានបំណងចង់ទៅកើតជាមួយយើង ចូរខិតខំធ្វើបុណ្យតាមទំនងដែលយើងធ្វើហើយចុះ ហើយក៏ធ្វើកាលកិរិយា បដិសន្ធិនៅលើរាជរថដែលមកអំពីឋានតុសិត គាត់មានអត្តភាពកំពស់ប្រមាណ ៣

គាវុត ប្រដាប់ដោយគ្រឿងអលង្ការ ៦០រទេះកើតហើយក្នុងខណៈនោះ។ មានស្រីទេពអប្សរ ១០០០ នាក់ចោមរោម និងមានវិមានកែវប្រមាណ២៥ យោជន៍ កើតប្រាកដ ។

ក្រោយមក ព្រះសាស្តាទ្រង់បានជ្រាបរឿងរ៉ាវជីវិតរបស់អ្នកមានបុណ្យឈ្មោះធម្មិកឧបាសកហើយ ក៏ទ្រង់ត្រាស់ព្រះគាថាថាៈ

**ឥធ មោទតិ បេច្ច មោទតិ កតបុញ្ញោ ឧភយត្ថ មោទតិ**
**សោ មោទតិ សោ បមោទតិ ទិស្វា កម្មវិសុទ្ធិមត្តនោ។**

បុគ្គលអ្នកធ្វើបុណ្យទុក រមែងរីករាយក្នុងលោកទាំងពីរ គឺរីករាយក្នុងលោកនេះ ១ រីករាយក្នុងលោកខាងមុខ ១ បុគ្គលនោះរមែងរីករាយស្រស់ស្រាយ ព្រោះឃើញអំពើបរិសុទ្ធរបស់ខ្លួន ។

## សូមពុទ្ធបរិស័ទ្ធសិក្សាពីជីវិតរបស់បុគ្គលមានបុណ្យ

ម្យ៉ាងទៀត នៅក្នុងបិដកលេខ ៥២, មួយអន្លើដោយអដ្ឋកថាគាថាធម្មបទ លោកបានសម្តែងអំពីជីវិតរបស់អ្នកមានបុណ្យ គឺនន្ទិយឧបាសក ។ នន្ទិយឧបាសកនេះ គាត់គឺជាទានាធិបតីមួយរូបនៅក្នុងព្រះពុទ្ធសាសនា គាត់បានកសាងនូវសេនាសនៈ(កុដិ) វេរប្រគេនព្រះភិក្ខុសង្ឃដែលមានព្រះជាប្រធាន ដោយចិត្តជ្រះថ្លា វេររួចច្រួចទឹកស្រេចកាលណាស្រាប់តែវិមានប្រាសាទ កើតឡើងនៅឋានទេវលោកដ៏ល្អល្អះ មានស្រីទេពអប្សរ ១០០០ នាក់ រង់ចាំនៅ

ក្នុងវិមាននោះ ថ្ងៃមួយព្រះមហាមោគ្គល្លាន ដែលជាទុតិយសាវ័កកំពូលខាងឫទ្ធិ បាននិមន្តទៅកាន់ឋានទេវតា ឃើញវិមាននោះល្អមានតែស្រីទេពអប្សរ តែមិនមានទេវបុត្រ ដូច្នោះ ក៏សាកសួរនាងស្រីទេពអប្សរទាំងនោះថា តើនេះជាវិមានរបស់អ្នកណា ? នាងស្រីទេពអប្សរទាំងនោះតបថា នេះជាវិមានរបស់នន្ទិយឧបាសកក្រោយមក ព្រះមហាមោគ្គល្លានក៏បាននិមន្តត្រឡប់មកវិញ ហើយស្រីទេពអប្សរទាំងនោះ ក៏បានផ្ដាំនឹងលោកថា សូមលោកម្ចាស់ប្រាប់នន្ទិយឧបាសកផងថា ចូរឆាប់ទម្លាយភាជនៈឆ្នាំងដី ហើយកាន់យកភាជនៈមាសវិញ ។

ព្រះមហាមោគ្គល្លាន បានដឹងរឿងនេះហើយ ក៏យកទៅទូលព្រះមានព្រះភាគ ព្រះអង្គក៏បានត្រាស់ព្រះគាថាប្រារព្ធនឹងជីវិតរបស់នន្ទិយៈថា៖

**ចិរប្បវាសឹ បុរិសំ ទូរតោ សោត្ថិមាគតំ ញាតី មិត្តា សុហជ្ជា ច អភិនន្ទន្តិ អាគតំ តថេវ កតបុញ្ញម្បិ អស្មា លោកា បរំ គតំ បុញ្ញានិ បដិគ្គណ្ហន្តិ បិយំ ញាតីវ អាគតំ ។**

ពួកញាតិក្ដី មិត្តក្ដី សំឡាញ់ក្ដី រមែងត្រេកអរនឹងបុរសដែលឃ្លាតគ្នាអស់កាលយូរ មកអំពីចម្ងាយដោយសួស្ដី មកដល់ហើយយ៉ាងណាមិញ បុណ្យទាំងឡាយ តែងទទួលបុគ្គលដែលបានធ្វើបុណ្យ ច្យុតអំពីមនុស្សលោនេះទៅកាន់លោកខាងមុខ ដូចញាតិទាំងឡាយទទួលបុរសជាទីស្រឡាញ់ ទើបមកដល់ ដូច្នោះឯង ។

## បទពិចារណា(បុណ្យកុសល)

-បុណ្យកុសលមិនដែលភ្លេចម្ចាស់ឡើយ→ មិនប្រទូស្តម្ចាស់ទេ

-បុណ្យកុសលមិនលំបាកថែរក្សា មិនភ័យខ្លាចបាត់ (ចោរលួចមិនបាន) មិនភ័យខ្លាចភ្លើងឆេះ មិនភ័យខ្លាចលិចទឹក។

-សន្សំបុណ្យឲ្យបានច្រើន → **កើនអរិយទ្រព្យ**

-អស់ប្រាក់ឲ្យតែនៅក្នុង ប្រយ័ត្នអស់ទាំងប្រាក់ អស់ទាំងបុណ្យ ព្រោះធ្វើបុណ្យអត់លះបាប មានន័យថា ធ្វើបុណ្យក្នុងបាប។

*ម្ចាស់អាចភ្លេចបុណ្យ តែបុណ្យមិនចេះភ្លេចម្ចាស់ទេ ឯបាបក៏ដូច្នោះដែរ គឺស្វែងរកម្ចាស់ទាល់តែឃើញ។

*ក្រលោកទ្រព្យ តែមានអរិយទ្រព្យ

*ក្រប្រាក់ តែមានធម៌ មានគុណធម៌: ក្រក្រៅ មានក្នុង។

*ក្រទ្រព្យ តែមានទ្រព្យ ។

**✍.ក្រទ្រព្យជារឿងធម្មតាទេ តែបើក្របុណ្យវិញគឺជាការក្រអ្វីៗទាំងអស់។**

**សរុបសេចក្តីមក** សៀវភៅ **ឧបមាជីវិត** នេះ សម្តែងអំពីជីវិត មានឧបមាដោយធម៌ ៣ យ៉ាងគឺ ៖

១/ សម្តែងអំពី ជីវិត មានប្រមាណតិចតួច ។

២/ សម្តែងអំពី ជីវិត មិនមានគ្រឿងការពារថា កុំចាស់...។

៣/ សម្តែងអំពី ជីវិត ត្រូវមានទីពឹង ពោលគឺសេចក្តីល្អ ។

គ្រប់ជីវិតរបស់សព្វសត្វទាំងអស់ ដែលបានកើតមកហើយនៅក្នុងលោកនេះ តែងជួបប្រទះនូវធម៌ ៣ ឬហៅម្យ៉ាងទៀតថា **មត៌កនៃជីវិត** គឺ ចាស់, ឈឺ, ស្លាប់ ។ ព្រោះហេតុនោះហើយ បានជាព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ដាស់តឿន ទូន្មាន ប្រៀនប្រដៅជារឿយៗនូវយើងគ្រប់គ្នា ដែលត្រូវលះបង់នូវអ្វីៗគ្រប់យ៉ាងដែលមាននៅក្នុងលោកនេះ ទៅកាន់លោកមួយទៀតនោះថា **អាយុរបស់មនុស្សទាំងឡាយនេះតិច សប្បុរសគួរខ្ពើមឆ្អើមអាយុនោះ បុគ្គលគួរប្រព្រឹត្តសុចរិតធម៌ ឲ្យដូចជាបុគ្គលដែលភ្លើងឆេះក្បាល ព្រោះថា ដំណើរមិនមកនៃសេចក្ដីស្លាប់មិនមានឡើយ។**

## សូមពុទ្ធបរិស័ទសិក្សាគាថាព្រះរដ្ឋបាល ដែលលោកបានសម្ដែងថ្វាយព្រះបាទកោរព្យរាជ

-អាត្មាភាព ឃើញពួកមនុស្សអ្នកមានទ្រព្យក្នុងលោក បានទ្រព្យគាប់ចិត្តហើយ មិនឲ្យទាន ព្រោះតែសេចក្ដីវង្វេង ។

-ពួកមនុស្សបានទ្រព្យហើយ ក៏ធ្វើនូវការសន្សំទុក ព្រោះជាប់ជំពាក់នឹងទ្រព្យ រឹងរឹតតែប្រាថ្នានូវកាមទាំងឡាយ ឲ្យក្រៃលែងទៅទៀត ។

-ព្រះរាជាឈ្នះមនុស្សលើផែនដី ហើយគ្រប់គ្រងសម្បត្តិលើ

ផែនដី មានសមុទ្រជាទីបំផុត នៅតែមិនស្កប់នឹងប្រទេសខាងអាយសមុទ្រ តែងប្រាថ្នានូវប្រទេសខាងនាយសមុទ្រទៀត ។

-ព្រះរាជាក្តី ពួកជនដទៃច្រើននាក់ក្តី មិនទាន់ប្រាសចាកតណ្ហាហើយ រមែងដល់នូវសេចក្តីស្លាប់ គឺថា ជាអ្នកមានសេចក្តីខ្វះខាត លះបង់នូវរាងកាយ ព្រោះថា សេចក្តីឆ្អែតឆ្អន់ដោយកាមទាំងឡាយ រមែងមិនមានក្នុងលោកជាដាច់ខាត ។

-ពួកញាតិ រំសាយសក់ កន្ទក់កន្ទេញចំពោះបុគ្គលដែលស្លាប់ហើយនោះ ទាំងបាននិយាយថា ធ្វើម្តេចហ្ន៎ ញាតិរបស់យើងទាំងឡាយកុំស្លាប់វិញ ក៏នាំខ្មោចនោះ ដែលរុំដោយសម្ពត់ ទៅកាន់ជើងថ្ករ ហើយប្រជុំគ្នាដុតក្នុងទីនោះ ។

-បុគ្គលដែលស្លាប់នោះ ត្រូវពួកអ្នកដុតចាក់ដោយឈើស្ងួល បុគ្គលនោះលះបង់នូវភោគៈទាំងឡាយ មានតែសម្ពត់មួយស្លាប់ទៅ ញាតិទាំងឡាយក្តី មិត្តទាំងឡាយក្តី ឬសម្លាញ់ទាំងឡាយក្តី ជាទីពឹងមិនបានទេ ។

-ពួកទាយាទ(អ្នកត្រូវទទួលមត៌ក) រមែងនាំនូវទ្រព្យរបស់បុគ្គលដែលស្លាប់នោះទៅ ចំណែកសត្វដែលស្លាប់នោះ ក៏ទៅតាមយថាកម្ម ទ្រព្យបន្តិចបន្តួច កូនប្រពន្ធ មាសប្រាក់ និងដែន ក៏មិនជាប់តាមសត្វដែលស្លាប់នោះទេ ។

-បុគ្គលមិនមែនបានអាយុវែង ដោយសារទ្រព្យទេ ទាំងមិនមែនកម្ចាត់បង់ជរាបាន ដោយសារទ្រព្យដែរ ព្រោះថា អ្នកប្រាជ្ញទាំងឡាយពោលនូវជីវិតនេះថាតិច មិនទៀងទាត់ មានសភាពប្រែប្រួលជាធម្មតា ។

-ជនទាំងឡាយអ្នកស្តុកស្តម្ភក្តី និងអ្នកទ័លក្រក្តី រមែងប៉ះពាល់នូវផស្សៈ(មិនជាទីប្រាថ្នា) បុគ្គលពាល និងអ្នកប្រាជ្ញ រមែងប៉ះពាល់ដូចគ្នា ប៉ុន្តែបុគ្គលពាល បើមានសេចក្តីទុក្ខបៀតបៀនហើយ រមែងដេក(សោកស្តាយ) ព្រោះភាវៈនៃខ្លួនពាល ឯអ្នកប្រាជ្ញ បើទុកជាប៉ះពាល់នូវផស្សៈ ក៏មិនបានញាប់ញ័រ ។

-ព្រោះហេតុនោះ បុគ្គលបាននូវព្រះនិព្វាន ជាទីបំផុតនៃភពក្នុងលោកនេះ ដោយបញ្ញាណា បញ្ញានោះជាធម្មជាតិប្រសើរជាងទ្រព្យ ដ្បិតបុគ្គលទាំងឡាយ មិនទាន់បានសម្រេចប្រយោជន៍ រមែងធ្វើនូវបាបកម្មទាំងឡាយក្នុងភពតូចនិងធំ ព្រោះតែមោហៈ ។

-បុគ្គលឯណា (បានធ្វើបាបកម្ម) ក៏ដល់នូវការអន្ទោលទៅមករមែងចូលទៅកាន់គភ៌ និងបរលោក បុគ្គលអប្បប្រាជ្ញា(ឯទៀត) កាលបើជឿបុគ្គលអ្នកធ្វើបាបកម្មនោះ ក៏ទៅកាន់គភ៌ និងបរលោក ។

-ចោរអ្នកមានធម៌អាក្រក់ ដែលគេចាប់បាន ត្រង់មុខតំណ(នៃផ្ទះ) រមែងក្តៅក្រហាយដោយកម្មរបស់ខ្លួន យ៉ាងណាមិញ សត្វ

អ្នកមានធម៌ដ៏លាមក លុះស្លាប់ទៅ រមែងក្តៅក្រហាយក្នុងលោកខាងមុខ ដោយកម្មរបស់ខ្លួនក៏យ៉ាងនោះដែរ ។

-កាមទាំងឡាយដ៏វិចិត្រ មានរសឆ្ងាញ់ ជាទីរីករាយនៃចិត្ត តែងញាំញីចិត្តដោយសភាវៈផ្សេងៗ បពិត្រមហារាជ ព្រោះហេតុនោះ អាត្មាភាពឃើញទោសក្នុងកាមគុណទាំងឡាយហើយ បានជាបួស ។

-មនុស្សទាំងឡាយ ទាំងក្មេងក្តី ចាស់ក្តី តែងបែកធ្លាយនូវសរីរៈ ដូចជាផ្លែឈើជ្រុះ(ចាកដើម) បពិត្រមហារាជ អាត្មាភាពបានឃើញនូវរបស់មិនទៀងនេះឯង បានជាចេញបួស ភាពជាសមណៈមិនសូវខុសភ្ញាត់ ជារបស់ប្រសើរលើសលប់ ។

# ចប់ សៀវភៅឧបមាជីវិត

## គម្ពីរជាឧបករណ៍ក្នុងការរៀបរៀងសៀវភៅនេះ

**-គម្ពីរព្រះត្រៃបិដករបស់ពុទ្ធសាសនបណ្ឌិត ព.ស. ២៤៩៩**

**-គម្ពីរអដ្ឋកថាពន្យល់សេចក្ដីនៃព្រះត្រៃបិដក ព.ស. ២៥២២**

**-វចនានុក្រម សម្ដេចព្រះសង្ឃរាជ ជួន ណាត ព.ស. ២៥១១**

-ព្រមទាំងឯកសារមួយចំនួនទៀត។

# **ព្រះពុទ្ធដីកា**

*នៅក្នុងបិដកលេខ ២៩, ទំព័រ ២៩៤ ព្រះមានព្រះភាគទ្រង់ត្រាស់ជាមួយនឹងមារមានចិត្តបាបថា ៖*

**អប្បមាយុ មនុស្សានំ**
**ហិឡេយ្យ នំ សុបោរិសោ**
**ចរេយ្យាទិត្តសីសោវ**
**នត្ថិ មច្ចុស្ស នាគមោតិ។**

*អាយុរបស់មនុស្សទាំងឡាយនេះតិច សប្បុរសគួរខ្ពើមឆ្អើមអាយុនោះ បុគ្គលគួរខំប្រព្រឹត្តសុចរិតធម៌ ឲ្យដូចជាបុគ្គលដែលភ្លើងឆេះក្បាល ព្រោះថា ដំណើរមិនមកនៃសេចក្ដីស្លាប់ មិនមានឡើយ ។*